ទុក្ខលំបាកឡើយទេ អស់មានទុក្ខភ័យរ៉ូវទៀតហើយ ដែលព្រលឹងនេះ កាលបើចេញអំពីព្រហ្មទៅហើយ ទៅព្រហ្មវិញបានឡើយទេ ទៅកើតជាមនុស្ស ឬ ប៊ូ ទុក្ខលំបាក ហើយបេះតែកើតតទៅទៀត បានទុក្ខលំបាក មិនមែនសុទ្ធតែកើតជាមនុស្សដកបតទៅទេ ដួនកាលកើតជាសត្វតិរច្ឆាន ជាសត្វនរកទល់ទុក្ខ ឬ ក៏ត្រឡប់មកកើតជាមនុស្សវិញ ល្អខ្លះ អាក្រក់ខ្លះ វិលវល់ទៅមកយ៉ាងនេះ ៗ នេះហើយជាដើមកំណើត ដែលនាំឲ្យកើតពាក្យថា «សង្សារ» ពាក្យថា សង្សារនេះ កើតមានមុនពុទ្ធសាសនាហើយ គឺកើតឡើងតាំងតែពីសម័យព្រាហ្មណ៍នេះឯង ។

អាត្មាដែលត្រូវវិលវល់កើតស្លាប់ បានទទួលទុក្ខលំបាកយ៉ាងនេះ មិនមានអំណាចទេពតាឃាត់ហាម មិនឲ្យកើតទៅទៀតបានទេ ព្រោះតែមាន «កម្ម» ដែលមនុស្សធ្វើ ។ ពាក្យកម្មនេះក៏កើតឡើង ពាក្យថា «កម្ម» នេះ ក៏មានមកហើយ

ក្នុងសាសនាព្រាហ្មណ៍ មុនកើតពុទ្ធសាសនាឡើង ។ សេចក្តីថា លុះត្រាតែធ្វើសេចក្តីល្អឲ្យលើសលប់ ឲ្យច្រើនគ្របលុបបាត់ការខុស ការអាក្រក់អស់ហើយ ទើបព្រលឹងត្រឡប់ចូលទៅកាន់ព្រហ្មវិញបាន នេះផុតទុក្ខអស់ហើយ មានតែសុខប្រសើរផុត ៗ សេចក្តីនេះ ប្រៀបដូចទឹកមហាសមុទ្រទៀត ទឹកទាំងអស់មិនថាទឹកអ្វីទេ សុទ្ធតែមកពីមហាសមុទ្រទាំងអស់ ទីបំផុតវិលចូលទៅកាន់នពមហាសមុទ្រវិញ តែមុននឹងចូលទៅនពមហាសមុទ្រ ត្រូវវិលវល់អស់កាលយូរណាស់ ចូលទៅទៅតាមជ្រោះជ្រលងផងស្ទឹងបឹងទន្លេ មិនងាយនឹងចូលទៅសមុទ្រវិញបានភ្លាមទេ ព្រោះស្ទឹងបឹងទន្លេ អាចនឹងកួចឲ្យវិលទៅវិញទៀត ឬជ្រាបចូលទៅក្នុងផែនដី គេផឹក គេប្រើប្រាស់ លាងគ្រឿងស្មោកគ្រោក ទៅជាទឹកស្អុយអាក្រក់ ឬទៅជាទឹកល្អស្អាត ឬពុំនោះទៅជាទឹកអប់ក្រអូប ទឹកមន្ត ឬទឹកថ្នាំអ្វីមួយ បើអាចចូលទៅកាន់នពមហាសមុទ្រវិញបានក៏

ត្រូវអស់កាលវេលាយូរអនេកវែង តែទោះដូចម្តេចក្តី ទីបំផុតទឹកនោះៗ ត្រូវតែហូរទៅកាន់មហាសមុទ្រវិញ ។

ដោយការជឿយ៉ាងនេះ សេចក្តីសង្ឃឹមរបស់មនុស្ស ទើបកើតឡើងថែមទៀត ជាសេចក្តីសង្ឃឹមដ៏មហាក្រៃលែង គឺសង្ឃឹមថា ខ្លួនគេបង្ឲ្យរួចការវិលកើតស្លាប់ ដែលជាសេចក្តីទុក្ខនៃសត្វលោក ដោយការប្រតិបត្តិឲ្យព្រលឹងចូលទៅរកព្រហ្មដែលមិនមានការកើតទៅទៀត ។ ការគិតឃើញទាំងនេះ បែកខ្នែងកើតទៅជាលទ្ធិសាសនា កើតមានសាស្ត្រាចារ្យទាំងឡាយច្រើននាក់ សុទ្ធតែព្យាយាមបំពេញខ្លួនឲ្យជួបវិធីដែលនាំព្រលឹងចូលទៅរកព្រហ្ម ឲ្យបានបំផុត ដែលខ្លួនអាចធ្វើបាន ដូច្នេះ សេចក្តីត្រូវការមនុស្ស ក៏ឡើងទៅកាន់ថ្នាក់ខ្ពស់មួយថ្នាក់ទៅទៀត គឺកាលដើមមុនលទ្ធិព្រហ្ម មនុស្សសែន បួងសួង បន់ស្រន់ទេវតា ដើម្បីឲ្យបានលាភសក្ការៈ

ដើម្បីសុខភាព ដើម្បីឲ្យមានកូនប្រុស ដើម្បីឲ្យមានអាយុវែង អនាគតជីវិត គឺ ការស្លាប់ទៅហើយ សូមឲ្យកើតទៀតបានល្អ ជាងជាតិនេះ ឬ ឲ្យកើតក្នុងឋានសួគ៌ តែលទ្ធិអាត្មន ជាផលរបស់ការមានព្រហ្ម ការគិតរបស់មនុស្សបានជឿនលឿនទៅខ្ពស់ទៀត គឺ ត្រូវការសេចក្តីសុខ ដែលមិនត្រូវកើតទៀត ដែលហៅថា "អម្ឫត=មិនស្លាប់" ។

ការផ្លាស់ប្តូរដ៏សំខាន់ដល់កម្រិតខ្ពស់នេះ កើតមកពីការប្រកាន់ជឿលទ្ធិអាត្មន ដែលជាលទ្ធិ "ខ្លួនឯង" ជំនឿដើមពីអតីតកាល គឺ ក្នុងសម័យអារ្យធម៌ សម័យត្រៃវេទ សេចក្តីល្អ សេចក្តីអាក្រក់ ផលអាក្រក់ ដែលកើតឡើងនោះ មិនមែនកើតឡើងដោយឯកឯងទេ គឺកើតឡើងដោយទេវតាបណ្តាលឲ្យ ទើបកើតឡើងបាន តែលទ្ធិ "អាត្មន-ខ្លួនឯង" មិនដូច្នោះទេ លទ្ធិអាត្មនបានសារភាពការជឿមួយទៀត គឺផលល្អផលអាក្រក់នោះ ជាអំពើរបស់ខ្លួន ដូច្នេះពាក្យថា "កម្ម"

ជាដើម ក៏ចាប់កំណើតឡើង ដោយអាស្រ័យការគិតទាំងអស់នេះ ជាបច្ច័យឲ្យមនុស្សចេះទទួលខុសត្រូវដោយខ្លួនឯង ។ លោកស្ត្រូស (Otto Strouss) ជាអ្នកប្រាជ្ញអាល្លឺម៉ង់ក៏សរសេរទុកថា លទ្ធិអាត្ម័ននេះ ជាការផ្តើមគំនិតមនុស្សឲ្យដើរទៅកាន់វិថីត្រូវ គឺទៅកាន់វិថីសម្មាទិដ្ឋិ នៅក្នុងវិថីពិតនៃមនុស្សជាតិ ជាការផ្តើមដ៏សំខាន់មួយដល់ចិត្ត ព្រមទាំងជាការប្រដៅមនុស្សឲ្យចេះដឹងទទួលខុសត្រូវដោយខ្លួនឯង ព្រោះកាលពីដើមឡើយ មនុស្សចង់បានអ្វីៗ ត្រូវសុំទៅទេវតា តែលទ្ធិអាត្ម័នប្រដៅថា ត្រូវធ្វើខ្លួនឯង ត្រូវពឹងខ្លួនឯង សូម្បីការចូលទៅកាន់ព្រហ្ម ឬ ចង់ឲ្យព្រលឹងរបស់ខ្លួនចូលទៅកាន់ព្រហ្ម ក៏មិនមែនសម្រេចដោយពឹងបួងសួងបន់ស្រន់ឬអាង សេចក្តីពិត គំនិតដែលកើតលទ្ធិព្រហ្ម គឺលទ្ធិអាត្ម័ននេះឡើង រៀនសែន បួងសួង បន់ស្រន់ បូជា សុំអ្វីពីទេវតានៅលើឋានសួគ៌ គេមិនសូវប្រកាន់ថាជាវិធីប្រសើរ គឺត្រូវតែ

ប្រតិបត្តិខានមិបាននោះទេ សូម្បីតែព្រះព្រហ្មដែលគេប្រកាន់ជឿថា ជាទេពតាខ្ពស់ផុតក៏ដោយ ក៏គេមិនធ្វើពិធីសែនបួងសួងបូជាដែរ គេមានពិធីប្រតិបត្តិប្រសើរមួយ ដែលគេបញ្ញត្តឲ្យកើតឡើង ជាពិធីខ្លួនឯងជួយខ្លួនឯង / គឺធ្វើដោយខ្លួនឯងក្នុងខ្លួនឯង ដើម្បីខ្លួនឯង ព្រោះខ្លួនឯងនោះគឺព្រហ្ម ការធ្វើដោយខ្លួនឯងជាអំពើរបស់ព្រហ្ម ការប្រព្រឹត្តប្រតិបត្តិបែបនេះបានឲ្យកើតលទ្ធិមួយទៀត ហៅថា «ឧបនិស័ទ» ។

៣– ឧបនិស័ទ. ឧបនិស័ទ ជាគម្ពីរមួយ កើតឡើងបន្ទាប់ពីសម័យព្រាហ្មណៈ គេហៅឈ្មោះមួយទៀត ជា «វេទាន្ត» ប្រែថា «ខាងចុងវេទ ឬថា កំពូលវេទ» ជាលទ្ធិដែលគេគន់គិតឃើញ ហើយគេបញ្ញត្ត សម្រាប់អធិប្បាយពន្យល់លទ្ធិព្រាហ្មណៈ ដែលមានការផុះផុលចំរើនទៅតាមកាលៈ ទេសៈ ឬ បើនិយាយមួយបែបទៀតគឺ «ជាពាក្យអធិប្បាយពន្យល់គោលលទ្ធិព្រហ្មនិកាយ» ។

គម្ពីរឧបនិស័ទ មានបែបបទដូចគម្ពីរវេទដែរ មានគម្ពីរដែលគេទុកជាកណ្តាល ហើយដែលគេទទួលស្គាល់ថាជាច្បាប់ពិតប្រាកដនោះទេ ព្រោះមិនមានការសន្នាយនា ដូចព្រះត្រៃបិដកក្នុងពុទ្ធសាសនា គឺជាគម្ពីរដែលមានមនុស្សច្រើននាក់សរសេរ ហើយចងជាទ្រឹស្តីតាមសេចក្តីយល់ឃើញរបស់ខ្លួនម្នាក់ ៗ បានរួមទៅជាគម្ពីរមួយនេះឡើង ក្នុងសម័យជាន់ក្រោយណាស់ទៅហើយ ។ គម្ពីរឧបនិស័ទនេះ កើតឡើងច្រើនសម័យច្រើនគ្រាណាស់ តាំងពីបុរាណព្រេងនាយ គឺសម័យពីបុរាណ សម័យកណ្តាល សម័យថ្មី តែគោលធំនោះ គេជឿកាន់គ្រប់សម័យ ព្រោះមានតែបំណងតែមួយ គឺស្វែងរកវិធីដែលនឹងធ្វើឲ្យព្រលឹងរបស់មនុស្ស វិលត្រឡប់ចូលទៅកាន់ព្រហ្មវិញប៉ុណ្ណោះ ។

លោក ឧត្តូ ស្ត្រូស (Otto Strauss) ជាអ្នកប្រាជ្ញអល្លឺ-ម៉ង់ ជាអ្នកត្រិះរិះវៃឆ្លាតល្អដ៏ឆាញម្នាក់ បានគ្រូគិតគំរិត

អាយុគម្ពីរឧបនិស័ទជាន់ចាស់បំផុតនោះ ត្រឹមវេលាមុនពុទ្ធកាល ប្រមាណជាមួយសតវត្សរ៍ គឺ ១០០ ឆ្នាំប៉ុណ្ណោះ ។ ពុទ្ធសាស-នានិងសាសនាជេនដែលកើតឡើងក្រោយ បានគន់គិតពិចារ-ណាបន្តទៅ តាមស្នាមគំនិតរបស់ឧបនិស័ទ ដែលគេគិតមកហើយដែរ មានគោលបំណងតែមួយ គឺបំបាត់ការវិលវល់កើតស្លាប់ ធ្វើវិញ្ញាណឲ្យរួចស្រឡះ ចាកការជំពាក់ទាំងឡាយដ៏បំផុតឲ្យបានលុះដល់ "មោក្ស=ការរួចស្រឡះ" គឺៈសុខក្តបរិ-សុទ្ធពិតប្រាកដ ហើយនឹងបានត្រឡប់ចូលទៅកាន់ព្រហ្មវិញមួយទៅទីណាក៏ដោយ តែគោលបំណងនៅត្រង់ឲ្យអស់ការកើតតទៅ ៗ ដើម្បីឲ្យលុះផលប្រសើរនោះ មនុស្សទាំងឡាយត្រូវធ្វើដោយខ្លួនឯង មិនមែនត្រូវធ្វើដោយពិធីសែនបួងសួងបន់ស្រន់ទេពតាដូចកាលដើមទេ ។

សេចក្តីខាងលើបន្តិចនេះហើយ ដែលពួកអ្នកប្រាជ្ញច្រើននាក់ ទាំងអឺរ៉ុបនិងទាំងអាស៊ី បានបបួលគ្នានិយាយថាពុទ្ធ-

សាសនាទិដ្ឋិសាសនាដទៃខ្លះ ប្រសូតចេញមកពីសាសនាព្រាហ្មណ៍ តែទោះបីជាដូចណាក៏ដោយ យើងជាអ្នកកាន់ពុទ្ធសាសនាគឺកាន់ខាងថា ពុទ្ធសាសនាកើតក្រោយមែន មើលទៅឃើញដូចជាមានស្នាមតំខិតជាប់គ្នាបន្ទុក តែអ្នកដើរមុនគេស្ទូចផលមិនទាន់ឃើញទេ មានតែព្រះពុទ្ធមួយអង្គប៉ុណ្ណោះ ដែលគេស្ទូចផលឃើញ ហើយយកដៃយក្រោយបំផុតបាន។ សេចក្តីពិតព្រះពុទ្ធទ្រង់ព្រះបហារៈមិនធ្វើតាមព្រាហ្មណ៍ទេ ព្រះអង្គមានទ្រឹស្តីផ្សេងពីព្រាហ្មណ៍ស្រឡះ ដូច្នេះ យើងហ៊ានពោលថា ពុទ្ធសាសនា មិនមែនជាលទ្ធិដែលប្រសូតចេញពីសាសនាព្រាហ្មណ៍ដូចអ្នកផងពោលនោះទេ ព្រោះពិធីព្រាហ្មណ៍ទ្រង់បានលះបង់ចោលអស់ហើយ កាលទ្រង់សិក្សាពីតាបសទាំងពីរនាក់ ។

ដើម្បីឱ្យបានលុះផលខ្ពស់ផុត ឧបនិស័យជាន់ចាស់បានពោលទុកថា មាន ២ ប្រការគឺ :

១- ហៅថា "តបៈ" ជាវិធីចាស់តាំងតែពីសម័យវេទ តែមានការផ្លាស់ប្ដូរច្រើនជនិមកហើយ ៗ ក្នុងសម័យវេទ ការបំពេញតបៈបានដល់ការសែនបួងសួង តែមិនមែនបួងសួងតាមធម្មតាទេ គឺត្រូវធ្វើយ៉ាងម៉ឺនម៉ាត់ ដោយព្យាយាមធំបំផុត ត្រូវអង្គុយសែនបួងសួងបូជារាល់ព្រឹករាល់ល្ងាច ឬ ច្រើនយប់ច្រើនថ្ងៃ ៗ មួយទៀត ពាក្យថា តបៈ មានន័យថា "សេចក្ដីព្យាយាមប្រឹងប្រែង" ឯសេចក្ដីព្យាយាមប្រឹងប្រែងនេះផ្លាស់ប្ដូរទៅជា ៣ ជាន់គឺ:

ក- ខាងដើមសម័យវេទ ការប្រឹងប្រែងក្នុងបូជាដែលហៅថា "តបៈ" នោះ ដោយមានបំណងឲ្យទេពតាឃើញចិត្តថ្លើមខ្លួន ហើយករុណាប្រទានអ្វីមួយដែលយើងសុំ រួមសេចក្ដីថី គឺសុំករុណាពីទេពតា ៗ

ខ- ខាងចុងសម័យវេទ ការបំពេញតបៈ មិនមែនសុំករុណាពីទេពតាទេ តែជាកិច្ចបង្ខំទេពតា គឺបើបានបំពេញតបៈ

ត្រឹមត្រូវហើយ ជឿថាទេវតាអត់ទ្រាំមិនបាន ត្រូវតែប្រទានអ្វីមួយតាមការសុំ ។ ការគោរពភ្លើងគុលទៅមុខអគ្គិយេស្ស៊ីន ស្វាធិគាថា ជាពិធីរបស់តបៈក្នុងសម័យខាងពុងវេទនោះ គេជឿថា ភ្លើងខ្ទង់ឡើងទៅបណ្ដាលឲ្យក្ដៅដល់ទេវតា ហើយទេវតាត្រូវអំណាចតបៈនោះ បង្ខំឲ្យព្រមឲ្យផលសម្រេចអ្វីមួយ តាមប្រាថ្នាអ្នកបំពេញតបៈ ។ ក្នុងវេលានេះ ពាក្យតបៈមានន័យថា «ក្ដៅ» ។

គ– សម័យព្រាហ្មណៈ ពាក្យថា តបៈ ក៏នៅមានន័យថា «ក្ដៅ» ដែរ តែមិនមែនធ្វើឲ្យទេវតាក្ដៅទេ លទ្ធិគាត់នជាលទ្ធិខ្លួនឯង តបៈបែបអាត្មន មានន័យថា «ធ្វើខ្លួនឯងឲ្យក្ដៅ» គឺការកាត់ខ្លួនឯង ឬ កាត់កិលេសដុតបំផ្លាញរបស់ដែលមិនបរិសុទ្ធឲ្យអស់ចេញពីខ្លួន ឲ្យសល់នៅតែសេចក្ដីបរិសុទ្ធិ ដើម្បីនឹងបានចូលទៅកាន់ព្រហ្មវិញ ។

មួយទៀត គំនិតនេះក៏កើតពីកម្មផែរ គឺយល់ថា ព្រលឹង

វិលវល់កើតស្លាប់យ៉ាងនេះក៏ព្រោះកម្ម គឺផលអាក្រក់ដែលត្រូវទុកក្នុងជីវិតនេះ ឬ ជីវិតពីអតីត ជាគ្រឿងសៅហ្មង បើបណ្ដោយតទៅ ទុកដូចជាបណ្ដោយឲ្យវិលវល់កើតស្លាប់ទៀត ឬក៏យល់ថា កិលេសជាគ្រឿងសៅហ្មងដូចជាតណ្ហា កត:ជាហេតុឲ្យមនុស្សធ្វើអំពើអាក្រក់នេះ កើតមកពីផាសុកនៃកងកាយ ឬកើតមកពីការប្រាថ្នាផាសុក វិធីដែលរំលត់សេចក្ដីប្រាថ្នាទាំងនេះ គឺការទូន្មានកាយ កាលបើកង្កាយមិនដឹងផាសុកហើយ សេចក្ដីប្រាថ្នា ដែលជាហេតុនៃកម្មខ្ចង់មិនកើតឡើងទេ កិលេសទាំងឡាយដែលមានហើយក៏អស់ទៅៗ ដូច្នេះ តបៈក្នុងសម័យព្រាហ្មណៈ ជារឿងទូន្មានកាយ ដែលពុទ្ធសាសនាហៅថា "អត្តកិលមថានុយោគ" ។

២- យោគ:- យោគ:នេះកើតក្រោយតបៈ កើតដោយសន្និយថា ព្រោះតបៈមិនបានផលល្អគ្រប់គ្រាន់ ។ លទ្ធិយោគ: បញ្ញត្តខុសពីតបៈ លោកឧត្តម ស្រុស អធិប្បាយ

ថា ការផ្សេងគ្នានៃតបៈនិងយោគៈនេះ គឺតបៈ ជាកិច្ចខាងកាយ យោគៈជាកិច្ចខាងចិត្ត តបៈទូន្មានកាយ យោគៈទូន្មានចិត្ត ។ តបៈគេជឿថា បើទូន្មានកាយឲ្យច្រើន នឹងរឹតតែបានល្អ ។ យោគៈគេប្រកាន់ថា ត្រូវតែរក្សាកាយទុកដោយប្រពៃបំផុត ទើបទូន្មានចិត្តបាន ។ យោគៈ ប្រែថា គ្រឿងទាញបង់គ្រៀក ដូចបង្កៀរបង់សេះឲ្យដើរទៅតាមប្រាថ្នាខ្លួន កាលបើយកពាក្យយោគៈនេះ មកប្រើខាងចិត្ត ក៏បានសេចក្ដីថា ចិត្តមនុស្សនេះ មានព្យសដូចជាសេះដែរ លទ្ធិយោគៈនេះជាគ្រឿងទាញបង់គ្រៀក ឃុំគ្រងឲ្យសេះគឺ ចិត្តមនុស្សនេះ ទៅតាមអំពើខ្លួនបាន ។ ដូច្នេះ ឧបនិបទ ជាការផ្ដើមគំនិតសសៀរចូលទៅរកចិត្តហើយ ។

លោក ឧត្តុ ស្រុស អធិប្បាយតទៅថា លទ្ធិយោគៈបានឲ្យអំណាចបដិសន្ធារដល់អ្នកហ្វឹកហ្វឺនហាត់ប្រតិបត្តិ តែគោលបំណងយោគពិតនោះ មិនមែនត្រឹមអំណាចចិត្តនោះ

ទេ នៅត្រង់ពាក្យថា "មោក្ស=ការរួចស្រឡះ" គឺការចូលទៅកាន់ព្រាហ្មណ៍ ។ មានវិធីហាត់ច្រើនបែបណាស់ក្នុងយោគៈ ដោយចំពោះ កាយបរិហារ គឺធ្វើកាយឲ្យមានសុខភាពល្អ ឲ្យមាំមួនដល់ចិត្ត មានរបៀបអង្គុយ ហាត់ដង្ហើមចេញចូល វិធីខ្ជាប់គំនិតមិនឲ្យទាក់ទងនឹងអារម្មណ៍ពីខាងក្រៅ ឲ្យចិត្តជាសមាធិ ហើយឲ្យចិត្តដឹងថា ខ្លួនឡើងខ្ពស់ចេញពីលោកដែលយើងឃើញដោយភ្នែកធម្មតានេះ ហើយចិត្តចូលទៅកាន់លោករបស់ព្រហ្មហើយ ។

អ្នកប្រាជ្ញល្បីបំរាំងមួយរូបទៀតឈ្មោះ អុលដង់ប៊ើគ៍ (Oldenberg) អធិប្បាយថា យោគៈគឺការធ្វើឲ្យស្ងប់ស្ងាត់ ហើយព្យាយាមឲ្យឃើញភាពដទៃ ១ ដែលមិនមែនជាភាពប្រក្រតី ព្យាយាមកំចាត់បង់នូវគ្រឿងប៉ះពាល់ទាំងរបស់ដែលប្រព្រឹត្តទៅបាន និងប្រព្រឹត្តទៅមិនបាន កំចាត់អ្វីមួយដែលជាសមត្ថភាពរបស់ចិត្តឲ្យអស់ចេញទៅ ឲ្យដឹងខ្លួនថាខ្លួនឡើង

ទៅលើតួតសភាពធម្មតានៃលោក ព្រមទាំងទៀងទៅនៅគង់លោកណាមួយទៀត ដែលខ្ពស់ជាងលោកនេះឡើយ ។

លោកពត្រីម៉ុន សាស្ត្រាចារ្យខាងទស្សនវិជ្ជាបំភ្លឺ ជាប្រធានាធិបតីក្រុមទេសភណ្ឌ អត្ថបូកថា លោកៈ ជារឹង ហាក់ចិត្តប្រៀបទាំងទៅកន្លែងយ៉ាងប្រសើរ ជាលទ្ធិដែលមានគុណ សម្បូរណ៍គ្រប់ទិសទាំងអស់ មិនបាច់ទាក់ទងជាមួយទេភតាកន្ធិណាមួយទេ ។ ហេតុនេះគេប្រកាន់ថា ចិត្តជាតបជាតិបរិសុទ្ធ ដោយធម្មជាតិ គ្រឿងសៅហ្មងទាំងឡាយដែលមាន ក៏កើតមានជាខាងក្រោយទេ សេចក្តីបរិសុទ្ធនៃចិត្ត មិនបាច់សាងទេ មិនត្រូវធ្វើអ្វីទេ ព្រោះបរិសុទ្ធស្រាប់ហើយ គ្រាន់តែជម្រះលាងគ្រឿងជំពាក់ គ្រឿងប្រឡាក់ឲ្យអស់ចេញទៅតែប៉ុណ្ណោះ ក៏បានការស្រេចហើយ បើលាងជម្រះឲ្យស្អាតហើយ ចិត្តក៏នៅតែជាចិត្តបរិសុទ្ធដដែល ចិត្តពិតប្រាកដនោះឯងគឺហេតុ, ចិត្តពិតប្រាកដនោះឯង គឺការបួលទៅ

ផល់ព្រៃ ៗ គំនិតលោកតាជក្រឹមណ្ឌនេះ ជាគំនិតថ្មីដកស្រង់ យកត្បូងកាសិតមកប្រើ ដើម្បីឲ្យឃើញថាអ្វី ៗ ក៏ជារបស់លម្អ ហិរញ្ញដែរ ដូចត្បូងកាសិតជា ឬកស្បូវមិនធំ ក៏ត្រូវ ចំណុំ លោកយកប្រើក្នុងប្រយោគទាន់ៈលើនេះ ៗ

X

X X

# សន្និដ្ឋាន

តាមការសង្កេតទូទៅ យើងបានឃើញថា ជីវភាពនៃប្រជាជនសកលលោក មានមុខងារច្រើនប្រការណាស់ មុខងារខាងផ្លូវចិត្ត សង្គមកិច្ច មុខងារចំពោះបុគ្គលម្នាក់ ៗ ជាដើម មុខងារទាំងអស់នេះ ដោយពិត ច្រើនតែកើតចេញមកពីលទ្ធិសាសនា ។ ការសង្កេតជូបពេលមកនេះ ឃើញមានសេចក្តីពិតច្រើនណាស់នៅក្នុងអារ្យធម៌ឥណ្ឌា ។ ដូច្នេះ សាសនាជាមេបង្កើតមុខងារ ។ មុខងារនេះ កើតបានទៅជាទំនៀមទម្លាប់, ទំនៀមទម្លាប់ក៏កើតចេញទៅជាប្រពៃណីនិយមតទៅទៀត ។ នេះហើយជាបាទសារវត្ថុនៃកត្តារបស់អារ្យធម៌ឥណ្ឌាទាំងមូល ។

តទៅ យើងគប្បីសិក្សាលទ្ធិសាសនាឥណ្ឌាតាមទិដ្ឋភាពខាងផ្លូវចិត្ត និងខាងសង្គមកិច្ច ។ ក្នុងការផ្ដើមសិក្សា យើងគប្បីយកស្ថាប័នសាសន.ឥណ្ឌាពីបុរាណមកពិចារណា ទើប

យើងនឹងអាចយល់នូវលក្ខណៈនៃសង្គមឥណ្ឌាបានដោយច្បាស់លាស់ គឺយើងត្រូវយកប្រពៃណីបុរាណ ដែលជាអារ្យ-ធម៌នៃវេទកសើ គឺជនជាតិមុនទ្រាវីឌ ដែលជាអ្នកដើមកំណើតប្រទេសឥណ្ឌាព្រមទាំងប្រពៃណីអារ្យធម៌ដែលទើបមកថ្មី មកទុកជាវត្ថុធាតុសម្រាប់ពិចារណា តែកិច្ចការទាំងនេះពិបាកពេកដូចជាហួសវិស័យនឹងធ្វើទៅបាន ដោយព្រោះហេតុតែយើងមិនមានឯកសារគ្រប់គ្រាន់ ។

យើងបានដឹងថា ប្រទេសឥណ្ឌាខាងទក្សិណាបថ មិនបានទទួលយកអារ្យធម៌ថ្មី ដែលជារបស់អារ្យន នៅខាងឧត្តរាបថច្រើនប៉ុន្មានទេ ។ យើងអាចរកឯកសារបុរាណក្នុងកាលនោះបានខ្លះនៅក្នុងបច្ចុប្បន្នកាលនេះដោយអាស្រ័យឯក-សាររបស់សង្គមជនជាតិ ទ្រាវីឌ ដែលនៅសល់ខ្លះ ៗ ប៉ុន្តែការនេះ ហាក់ដូចជាចូលក្នុងសេចក្តីព្រហើនបន្តិចទៅហើយព្រោះហ៊ាននិយាយដល់សភាពសង្គមជនជាតិឥណ្ឌាមុនអារ្យន

ដែលហៅថា ព្រាវិឌ កាលពី ១៥០០ ឆ្នាំ ឬ ២០០០ ឆ្នាំមុន គ្រិស្តសករាជ ។ មួយទៀតជនជាតិ ព្រាវិឌ **នេះ ពីបុរាណ** មិនមានគោលអ្វីជាលាយលក្ខណ៍អក្សរល្បះសិក្សា**បានទេ** មាន **តែចាំទន្ទេញ** ដែលមាននៅសល់ហើយជាប់លាយ**ចូលក្នុងគម្ពីរវេទ** ខ្លះម៉ឹណ្ណះ ។ ដោយការមិនសូវសម្បូណ៌ឯ**កសារនេះ**ឯង យើងគ្រាន់តែពិចារណាគោលលទ្ធិ វណ្ណា មុនគម្ពីរ**វេទ**ដោយ សង្ខេបៈ នៃការសិក្សាសង្គមវណ្ណា ឲ្យបានយល់ គឺត្រូវតែ សិក្សាគម្ពីរវេទនេះផង ព្រោះវេទជាបាវនៃសង្គមវណ្ណា ។

វេទ ប្រែថា "ការចេះដឹង" ជាឈ្មោះគម្ពីរសក្តិសិទ្ធិ របស់ព្រាហ្មណ៍មាន ៤, តែកាលដើម មានតែវេទ ៣ ទេ ដែលយើងហៅថា "ត្រៃវេទ" ។ ក្រុមវេទមួយ ៗ ហៅថា "សំហិតា" ប្រែថា "ការប្រមូល, ការចងក្រង ឬ ក្រុម" គឺ:

១– ឫគ្សំហិតា ឬ ឫគ្វេទ

២-សាមសំហិតា ឬ សាមវេទ

៣-យជុះសំហិតា ឬ យជុវេទ

៤-អថវ៌សំហិតា ឬ អថវ៌វេទ

កាលបើគេនិយាយថា "ត្រៃវេទ" គេបន្ថែម "អថវ៌-វេទ" មួយទៀត ព្រោះវេទនេះជាគម្ពីរថ្មី ដែលគេបន្ថែមក្នុងកាលជាន់ក្រោយ ៗ គម្ពីរពុទ្ធសាសនា ហៅគម្ពីរវេទទាំង ៤ នេះថា ឫគ្វេទ សាមវេទ យជុវេទ និង អាថព្វណវេទ ៗ ក្នុងគម្ពីរវេទមួយ ៗ មានគម្ពីររងមួយ ៗ ជួយពន្យល់ទំនងដូចជាអដ្ឋកថាព្រះត្រៃបិដកយើងដែរ ហៅថា ព្រាហ្មណៈ អារណ្យកៈ ឧបនិសទ មួយ ៗ ជាប់នឹងគម្ពីរវេទមួយ ដូចឯតរេយៈ ព្រាហ្មណៈ ជាប់នឹង ឫគ្វេទ ; ឆន្ទោគ្យ ឧប-និសទ ជាប់នឹង សាមវេទ ដូច្នេះជាដើម ៗ

"ព្រាហ្មណៈ" ជាគម្ពីរមួយនិយាយពីវិជ្ជាសក្តិសិទ្ធិរបស់ព្រាហ្មណ៍មាន ២ ប្រការគឺ វិធី (Prescriptions) ១,

អដ្ឋកថា (Explications) ១, ហើយមាន "គាថា" ឬ "លទ្ធិ" (Ecoles) ច្រើនគំនរទៀត ។

"អារណ្យក:" ប្រែថា "អត្ថបទនៅព្រៃ" និយាយពីការសង្ងាត់កំបាំង (រហស្យ) ដែលត្រូវរៀននៅឆ្ងាយពីគេ ក្រៅពីពួកគណ: គឺនៅក្នុងព្រៃ:ចំបច្ចេទន ។

"ឧបនិស័ទ" ប្រែថា "អត្ថិយជិត" គឺជាបទដែលត្រូវកកក្លាយមកពីបទព្រាហ្មណ: នៃអារណ្យក: ។ ល ។

វេទាង្គ: ប្រែថា "អង្គនៃវេទ" ជាផ្នែកពិប្បាយពន្យល់ វេទមាន ៦ ប្រការ គឺពន្យល់ពី សិក្សា (La Phonetique), កល្ប: (Le Rituel), វ្យាករណ: (La Grammaire) និរុក្ត (L'Etymologie), ឆន្ទ (La Métrique), ជ្យោតិស (L'Astronomie) ។

វេទាង្គនេះ សម្រាប់រៀនគឺត្រូវរៀនឲ្យចាំមាត់ ហើយត្រូវមានគ្រូពន្យល់ទៀត ៗ ឯក្រៅគសូត្រ និយាយពីការប្រមូល

ទាក់ទាមការរៀនជាលំដាប់យជ្ញ:, គ្ឫហ្យសូត្រ និយាយពីពិធីប្រសិទ្ធិការ ឬ ធ្វើមង្គល ហៅថា "សំស្ការ= ការធ្វើឲ្យបានប្រសើរ, ប្រសិទ្ធិ" ។ គម្ពីរទាំងពីរនិយាយពីកល្ប: ហៅថា កល្បសូត្រ: ។ សូត្រ:ដទៃទៀតនិយាយពីច្បាប់ ខាងសីលធម៌ ឬ ខាងសាសនា ហៅថា ធម៌សាស្ត្រ ។ នៅក្នុងក្រុមគម្ពីរលោកកាត្យាយន (Kâtyayana) មានតែស្រៅត-សូត្រ និង សុល្វសូត្រ:, នៅក្នុងក្រុមគម្ពីរលោកអស្វលាយន (Açvalâyana) មានតែស្រៅតសូត្រ និង គ្ឫហ្យសូត្រ ។ ឯក្រុមគម្ពីរលោកអាបស្តម្ព (Apastamba) និង លោកពោធាយន (Baudhâyana) ទើបមានស្រៅតសូត្រ, គ្ឫហ្យសូត្រ, ធម៌សាស្ត្រ និង សុល្វសូត្រ គ្រប់ទាំងកល្បសូត្រ ៤ គម្ពីរទៀតផង ។ តារាងភ្ជាប់ជាមួយនេះមិនបានដាក់សព្វគ្រប់ទេ(១) ។

---

១– សូមមើលតារាងភ្ជាប់នៅភាគក្រោយបង្អស់ ។

ការបូជាក្នុងគ្រួសារ ៖— ពិធីបូជា(១)ដែលមានក្រាំងទុកក្នុងគម្ពីរឬគ្រូ គឺពីតំណពូជមួយទៅពូជមួយទៀត រាប់ពាន់ឆ្នាំមកហើយ មានច្រើនបែបណាស់ មិនមែនមានតែបែបមួយជាប់រហូត គ្រប់កាលវេលាមកដល់បច្ចុប្បន្នកាលនេះទេ មានបែបផ្សេង ៗ កើតច្រើនឡើងមានការផ្លាស់ប្តូរ ឬមានការផ្ទុយខុសពីគ្នា ឬក៏មានការប្រែប្រួលទៅតាមលទ្ធិរបស់ខ្លួន ទៅតាមគ្រូ ទៅតាមកាល កើតបានទៅជាប្រពៃណីផ្សេង ៗ គ្នា ក្នុងគម្ពីរក៏មានប្រាប់ដែរថា មានពិធីខ្លះគេបោះបង់ចោលលែងប្រតិបត្តិតាមទៅហើយផង ។ មួយទៀតមានសេចក្តីថា ក្នុងវេទមានសេចក្តីបង្គាប់ឲ្យធ្វើដូចនេះ ដល់មកក្នុងសូត្រក៏ប្រាប់តែប្រាប់ថាឲ្យធ្វើដូចនោះទៅវិញ ។ ឈ្មោះយជ្ញកាណ្ឌ ឬ ហោម-កាណ្ឌ គ្រឿងឧបករណ៍សម្រាប់ធ្វើការបូជានៃពិធីសោមៈនិង

---

១- សេចក្តីពិស្តារ មើលសៀវភៅ Inde classique T. I., ពីទំព័រ ៦២៥ (Rituel) តទៅ ។

ឈ្មោះអ្នកបូជា ហោតា្ឫ ឬ ហវិរ័ន្ធ គឺមានផ្លាស់ប្ដូរដែរ ៗ
ពិធីបូជា ព្រោះមានបែបបទច្រើនណាស់ លោកអុលដេនប៊ែរគ៍
(OLbenberg) និយាយថា "មុខងារនៃព្រាហ្មណ៍និងបុរោ-
ហិត ដែលមានក្នុងគម្ពីរវេទ ហើយមិនស្របគ្នាតាម
ក្បួននៃពិធីទេ លោកប៊ែរគែញ (Bergaigne) និយាយថា
"ពិធីបូជា" មានកំណត់ក្នុងគម្ពីរវេទ, រីឯលោកហ៊ីល្លប្រ៊ែន
(Hille Brandt) និយាយថា គម្ពីរឫគ្វេទ មានការផ្លាស់
ប្ដូរពិធីបូជា ៗ លោកហែរតែល (Hertel) និយាយថា ពិធី
អាប្រ៊ី (Apri) នេះធ្វើតែក្នុងពិធីបុណ្យចូលឆ្នាំថ្មី ដែលមានការ
ជាប់ទាក់ទងនឹងការឈប់ដើរនៃព្រះអាទិត្យ ក្នុងសិសិររដូវតែ
ប៉ុណ្ណោះទេ" ដូច្នេះជាដើម ៗ

ពិធីបូជាជាកិច្ចនៃអ្នកបួស; ការធ្វើបូជាហៅថា យជ្ញ-
ក្រិយា, យជ្ញ ឬ ហោមៈ ( Oblation ) ប្រែថា ការបោះ
គ្រឿងបូជា ហវិស (យជ្ញទ្រព្យ, ហវ្យៈ គឺ សប្បិ ហោមៈ

ទីរៈ ត្រាច់ស្រូវ) ឬ គល់ទៅកុដិភ្លើង ឬចាំបំពោះទេវតា ដែលជាការបូជាក្នុងគ្រួសារ (Culte familial) ដើម្បីឲ្យកើតសេចក្តីសុខ សេចក្តីចម្រើន មានសុខភាព មានអាយុវែង សម្បូរណ៍សត្វពាហនៈ ព្រមទាំងឲ្យបានកូនប្រុស តែនិយម ដែលគោរពយញ្ញៈនេះ មិនប្រព្រឹត្តទៅតាមសភាពពិតនៃពិធីកម្ម គម្ពីរវេទ ។ បើតាមលោកកេថ (Keith) ដែលជាអ្នកប្រ-កាន់តាមពិធីបូជានេះ យើងនឹងឃើញថា សេចក្តីបកស្រាយនៃលោកហ៊ុយប៊ែរ (Hubert) និងលោកម៉ោស្ស (Mauss) ត្រឹមត្រូវតាមគម្ពីរព្រាហ្មណ៍ពិតមែន គឺថា ពិធីបូជាជាការធ្វើឲ្យកើតភ័ក្តិសក្តិសិទ្ធិ សម្រាប់ធ្វើបុគ្គលដែលជាអសារជន (Profane) ឲ្យបានទៅជាបុគ្គលសក្តិសិទ្ធិ (Sacré) បានសេចក្តីថា ផ្លាស់ឲ្យកើតទៅជានីតិបុគ្គល (Personne morale) ដោយអំណាចនៃពិធីនោះ ។ ឯអ្នកសង្គ្រោះ (Victime) មនុស្ស ឬ សត្វ ដែលត្រូវគេយកទៅធ្វើជាគ្រឿងបូជា (យញ្ញវត្ថុ, ហវ្យៈ

ពលី) នោះ គ្រាន់តែជាការសម្រេចកិច្ច ឬ គ្រាន់តែជាការបន្ត បូជាសព្ទ ឬក៏ជាជាគមនាគមន៍រវាងអ្នកជា ជាតិជន និង បុគ្គល សក្តិសិទ្ធិតែប៉ុណ្ណោះ, អ្នកបួសនេះបានទុកជាអាណត្តិកជននៃអ្នក បូជា (ហោរ៉ែន ឬ ហោត្រ) ព្រមទាំងទុកជាប្រតិភូនៃទេវតា បានទៀតផង ។

ឯពិធីបូជាគ្រប់បែប ត្រូវមានសូត្រស្តុតិ (Prière) ជាដរាប, សូត្រតិច ១ តាមប្រមន្ត្រ "យជុស", សូត្រគ្រួញ ១ ហៅថា "ប្រណវ:" ហើយឲ្យមានពាក្យថា "ឱម" លាយឡំបន្តិច ។

គ្រឿងបូជា (យជ្ញទ្រព្យ:, ហវ្យ: ឬ ពលី) ត្រូវបោះ ចោលកណ្តាលនៅក្នុងភ្លើង (អគ្និ) ពាក់កណ្តាល ត្រូវទុកទៅ ជាអាហារនៃអ្នកបូជាដែលហៅថា ហោត្រ (Officiant) ដែល មានជីវិតទុកជាទេវតា, ឯអាហារគឺទុកដូចជារបស់ទិព្វដែរ ។ វត្ថុដែលត្រូវបូជា គឺជាផលិតផលដែលកើតបានមកពីស្រែការ

គឺទឹកដោះគ្រប់បែប ដូចជាសប្បិ (កក ឬ ជាដុំ) ពញ្ញោតិ (អង្ករដែលធ្វើជានំ)។ សត្វដែលគេសម្លាប់បូជា ហៅថា បសុពន្ធ ឬ បសុយាគ, វត្ថុដែលត្រូវបូជាក្រៅពីសត្វមានជីវិត ហៅថា ឥដ្ឋិយាគ: ។ សត្វដែលត្រូវបូជាគឺ ពពែ គោ លា ឆ្កែ ។ ឆ្កែសម្រាប់បូជា ចំពោះរក្សសៈ ។ ការបូជាសេះ ហៅថា អស្វមេធ: ជាពិធីធំមួយ, ឯការបូជាមនុស្ស គេទុកជាពិធីធំបន្ទាប់លើកមកទៀត ហៅថា បុរុសមេធ: ។ គម្ពីរ អត្ថិបយន:និយាយថា សត្វដែលគេត្រូវសម្លាប់ការពេលដើមមានដល់ទៅប្រាំ, មានមនុស្សម្នាក់ គេកាត់យកក្បាលទាំង ៥ នេះទៅលាក់ទុកក្នុងកំពែងឥដ្ឋ ហើយគេបោះខ្លួនទាំងប្រាំទៅក្នុងទឹក ។ មនុស្សនេះ ទោះជាព្រាហ្មណ៍ឬក្សត្រិយ៍ គេត្រូវទិញមកដោយតម្លៃ ១០០០ គោញី ឬក៏ ១០០ សេះ មុនសម្លាប់គេធ្វើដូចសេះដែរ គឺគេលែងឲ្យដើរទៅតាមចិត្តមួយឆ្នាំបានគេសម្លាប់, សម្លាប់ហើយព្រះអគ្គមហេសីស្តេចត្រូវទៅផ្ទុំ

នៅក្បែរភ្នំបនោះ ។

សោមៈ ជាទឹកស្រវឹង (ផឹកហួសកំណត់មានគ្រោះ) កើតពីរុក្ខជាតិ, អ្នកប្រាជ្ញយល់ថាជារុក្ខជាតិមួយបែបហៅថា Asclé-piade (លោក Jogeç, Chandra Ray ថា Asclépias acida: Chanvre ; លោក Aurel Stein ថា Rhubarbe sauvage ) ។ ពិធីធ្វើស្រា "សោម" នេះ គេត្រូវទិញរុក្ខជាតិសោមៈដោយតម្លៃគោមួយ ហើយត្រូវដាក់ទោសដល់អ្នកលក់ឲ្យថែមទៀតផង ត្រូវដាក់រទេះដឹក ឬ ទូលលើក្បាល រដ៏រជាក្បួនហៅយកមក ផងទឹកយកមកលាយកិនជាមួយសោមៈ យកជាតិទឹក ហើយច្រោះ យកទឹកជមមកដាក់ក្នុងថាំង លាយទឹក ទឹកដោះ ដូចកាលលាយទឹកឃ្មុំផង ។ គេសង្ស័យថា ប្រហែលជាសោមៈ ជាភេសជ្ជៈប្រើជាដំបូងទៅ បានជាគេប្រើជាធម្មតា ព្រោះភេសជ្ជៈដែលគេទុកជារបស់ជាកតាប ហើយគេហាមខ្លះផងនោះគឺសុរា ដែលគេមិនយកជាតិចម្រុះ-

ជាតិវង្ស ៗ ប្រើមួយដងមួយកាលតែក្នុងពិធី ពិសេសៈ នៅក្រោមខី ប៉ុណ្ណោះទេ ។

អ្នកធ្វើការបូជាសម្រាប់ខ្លួនឯងហៅថា យជមានៈ បើព្រះរាជា ជាយជមានៈ គឺមហាក្សត្រិយ៍ ព្រាហ្មណមហាសាល ជាអ្នកជាន់ខ្ពស់ក្នុងវណ្ណៈទាំង ៣ បើធ្វើជាឯកជន មានភរិយា ជាអ្នកជួយផង ប៉ុន្តែការសំខាន់នៅលើបុរោហិត ។

អ្នកចាត់ការបូជាហៅថា ហោត្រ (Officiant) ជាពាក្យពីបុរាណកាល (អវេស្ត: Zaoter= អ្នកបូស ) ដែលមានក្នុងគម្ពីរឫគ្វេទ ប្រែថា "អ្នកបោះ ឬ ចាក់" យញ្ញ ឬ ហោម លោកហែរតែល (Hertel) ប្រែថា "អ្នកហៅ" (Appeleur) ជាអ្នកសូត្របួងសួង តាមគាថាក្នុងឫគ្វេទ ។ ហោត្រនេះ កាន់មុខងារជាជាប់ខាតក្នុងពិធីយញ្ញ ដែលត្រូវអ្នករៀបចំដើមក្រោមអគ្គិ ប្រើប្រាស់យញ្ញកាណ្ឌ ឬ ហោមកាណ្ឌ (Instrument d'oblaton) បោះ ឬ ចាក់គ្រឿងបូជាយញ្ញទៀត

ឬ ហវ្យ (Objet servant au sacrifice) ។ ការថែរក្សាឬសំអាតវេទី គឺភ្លើងក្រានអគ្គិ ហៅថា អគ្នីធ (Agnidh) របកក្លាយទៅជាអាគ្នីធ្រ: (Agnjdhra) ប្រែថា "អ្នកបង្កាត់ភ្លើង" ។ ការបូជាភ្លើង ហៅថា ហោត្រ (Hotra) ឬ អគ្និហោត្រ (Agnihotra) ធ្វើដោយអ្នកចាត់ការម្នាក់បាន គឺព្រាហ្មណ៍អធ្វយុំ (Adhvaryu) តែពិធីបូជា សោម: ទាល់តែមានគ្នា ១៦ (ឬ១៧) នាក់ ទើបធ្វើបាន ហើយចែកជា ៤ ក្រុមទៀត នៅក្រោមអធិបតីភាព នៃហោត្រអធ្វយុំ ឧទ្គាត្រ និង ព្រាហ្មណ៍ ។

ទីឋានបូជា.— គម្ពីរវេទនិយាយថា មិនបាច់មានទីឋានរ គេធ្វើក្នុងផ្ទះឬវិហារ ទីវាលមានស្មៅក៏បាន គេតាំងភ្លើងក្រាន ៣ កន្លែង ទីកន្លែងនេះរៀបចំស្រេចសម្រាប់ព្រាហ្មណ៍យជមាន: និងភរិយា ឲ្យមានទឹក មានដំបូល ។ ទីកណ្ដាលគេតាំងវេទី (Autel) ទ្រង់ទ្រាយ ៤ ជ្រុងទ្រវែង ជ្រុងខុប

បន្ទិច ជាកន្លែងដែលគេសម្រាប់ដាក់តម្កល់គ្រឿងបូជា ល។ ចាប់ស្មៅដេរជាសរនៅជុំវិញ (ពហ៌ីស៍ (អវេស្ត:) ពរស៊ន, ពសិស៌ "ខ្នើយ") ដើម្បីទុកឲ្យទេវតា ចូលមកអង្គុយ ហើយបរិភោគគ្រឿងបូជា ៗ វេទីនោះ ជួនកាលធ្វើពីឥដ្ឋ មានទំហំធំទូលាយដែរ ៗ

ហើយធ្វើពិធីបូជា សោមៈ ត្រូវមានមហាវេទី (Mahavedi) ទ្រង់ទ្រាយ៤ជ្រុងព្នាយ ដើម្បីទទួលរបស់សម្រាប់សោមៈ ហើយមានឧត្តរវេទីមួយទៀត ព្រមទាំងមានកេងសម្រាប់ជា ធិស្ណ្យ គឺកន្លែងជ្រកកូនចៅនៃអ្នកចាត់ការបូជាផង ពិធីបូជាមានច្រើនណាស់តទៅទៀត, ក្នុងទីនេះនិយាយមិនអស់ទេ ៗ

ពិធីមហាវ្រត.– "មហាព្រត" ជាពិធីបញ្ចប់ការដើរនៃព្រះអាទិត្យក្នុងសិសិររដូវ (វស្សានរដូវ តាមលោកហ៊ីល្ល-ប្រ៊ិន), ឯលោកហៅវ័រ (Hauer) និយាយថាជាការតាច់កំបាំងមួយបែប ដែលគេធ្វើពេញទាំងប្រទេសក្នុងបុកណ

(Classique) មានភ្លេង ស្គរ ខ្លុយ មានរហាត់ជិះទោង (Escarpolette) យោល, មានជនកាយ៍ន និងជនគូព្រះ ដណ្ដាប់ស្បែកពណ៌សរនិងមូល មានកុមារីតំ ៗ លោកកេថ (Keith) និងលោកហៅវ៉ៃ យល់ថា ជាការធ្វើឲ្យកើតចំរុងចំរើន ៗ ទីបំផុត ទើបគេធ្វើជាក្បួនហែសំពះទៅ ស៊ីនសរស្មុគ ហើយធ្វើពិធីស្នានៈទៅវិនោះ ៗ ចាំងអស់នេះ កើតចេញមកពី "យាត្រា" បុកកា (Classique) ៗ

ពិធីកដបេយ.— កដបេយ "ការផឹកភេសជ្ជៈជ័យ-ជំនះ" ៗ ពិធីនេះកើតចេញមកពីពិធីសោមៈផែរ មានការបររថ ១៧ រឹមដោយសេះច្រើន បញ្ចុះអ្នកធ្វើការបូជាហើយបរទៅតាមផ្លូវជាគន្លង ដែលគេបាញ់សរឲ្យចរទៅ ១៧ សរ ព្រាហ្មណ៍ម្នាក់ជិះនៅកណ្ដាលរថ មានកង់ចក្រមួយនៅលើដងស្កាន ហើយគេបង្វិលកង់ចក្រនោះឲ្យវិលតាមផ្លូវដែលបររថទៅ ៗ ទីបំផុត មានពិធីឡើងទៅកាន់ព្រះអាទិត្យ, ពិធីនេះ

អ្នកធ្វើការបូជាព្រមទាំងភរិយា ត្រូវឡើងទៅកាន់កំពូលក្រធ្វើ មេឃ ដែលជារូបកាយនៃសូរ្យ ហើយដែលគេបង់នៅ បង្គោលខ្ពស់សក្តិសិទ្ធិមួយៗ ពិធីវាជបេយៈនេះ មានគេ រកឃើញច្រើន ដូចពិធី "រាជសូយ" ដែរ គេធ្វើ ១ពី ថ្ងៃទៅដល់មួយឆ្នាំក៏មានដែរ ។ នេះជាពិធីធ្វើឲ្យបានចំរុង បរេ្យីនដែរ ។ (Przyluski) និយាយថា ពិធីនេះ ដូចពិធី បូជាសេះនៃពួកប៉ាប៊ីឡូនី (Babylonie) ដែរ ។

ពិធីរាជសូយៈ– រាជសូយ "ព្រាក្តាភិសេក" ក៏ចេញ ពីពិធី "សោមៈ"ដែរ ប៉ុន្តែមិនជាបុកណាពេកទេ ។ ព្រាក្តា-ភិសេកដោយការស្រោចទឹក គឺហោត្រម្នាក់ជាអ្នកកំណាន់ស្រ្គ ទាំងឡាយមកស្រោចស្រប់ព្រះរាជា ដោយទឹកផ្សេងៗដោយ ទឹកសម្រិទ្ធិទឹកឃ្មុំ ដែលជាក់ក្នុងភាជន៍ជាវិការនៃឈើឧទុម្ពរ ព្រះ រាជាប្រថាប់នៅលើកដបក្ខ័ណ្ឌឈើឧទុម្ពរនេះដែរ តែត្រូវយក ស្បែកខ្លាគ្របពីលើ, នាម៉ឺនមុខមន្ត្រីនៅព័ទ្ធជុំវិញ, រឿងនេះជា

រឿងគួរពិតពិលរមិលមើលណាស់ ព្រះរាជាក្នុងគ្រើជាអ្នកលប ចូលទៅដណ្ដើមហ្វូងគោញីដែលជារបស់ផងញាតិណាមួយនៅជិតខាង (សេចក្ដីប្រែមួយទៀតថា ស្ដេចលបចូលទៅយករបស់ទ្រព្យញាតិជិតខាង) ហើយទ្រង់ប្រទានទ្រព្យឲ្យម្ចាស់ដើមវិញៗ នេះគឺជាទិដ្ឋភាពទាំងពីរនៃការបង្ហាញភាពជាស្ដេច គឺការដណ្ដើមរាជ្យ និងអធិរាជ្យ ។ មានកិច្ចការផ្សេង ៗ ទៀតសម្រាប់បញ្ចប់ពិធីនេះ គឺព្រះរាជាប្រថាប់នៅលើស្បែកខ្លា ក្រសាលបាស្កាជាមួយក្មួយ បើបាញ់ព្រួញសជាគោញី ៗ ឯយជ្ញទ្រព្យ គឺ ទក្ខិណា: គ្រាប់ទុស្ស១០ម៉ាត់ ផឹកសុរាជាមួយគ្នា ដោយតែង១០ផែ ៗ ភ្នាក់ងារទៅនៃរាជសូយៈនេះ មានតម្លៃច្រើនហួសប្រមាណពេកណាស់ ជូនការមានដល់ទៅ២៤០.០០០ គោ ក៏បាន ។

អស្វមេធ:.- អស្វមេធ "បូជាសេះ" ជាពិធីបូជាមួយធំ ស ប្រកបពិធីវេង ព្រោះជាការសំដែងតេជានុភាពនៃព្រះរាជា

ដែលទ្រង់មានជ័យ ៗ ពិធីនេះមានកំណត់ ៣ ថ្ងៃ តែការរៀបចំត្រូវប្រើវេលា ដល់ទៅមួយឆ្នាំ ឬពីរឆ្នាំ ហើយគេតែងតែធ្វើក្នុងខែកុម្ភៈ-មេសា ៗ ក្នុងពិធីនេះ មានហោរា ៤ នាក់ ព្រះអគ្គមហេសី ៤ អង្គ ព្រមទាំងព្រះកជបរិចារ ៤០០ នាក់ មានប្រជាជនច្រើនអនេក ៗ

លុះបានធ្វើកិ (Kite) ច្រើនបុនហើយ គេនាំយកសេះមួយមក ដែលជាពាហនៈដ៏មានតម្លៃ ហើយគេបោះឡោតក្ន មួយទៅក្រោយជើងសេះ ព្រមទាំងមានធ្វើហោមផ្សេង ១ ទៀត ទើបគេលែងសេះឲ្យដើរទៅតាមចំនើងវា ជាមួយនឹងសេះដទៃទៀតចំនួន ១០០, មានពលមនុស្សកម្លោះ ៤០០នាក់ ដើរតាមក្រោយសម្រាប់ថែរក្សាព្រមទាំងប្រយុទ្ធចំពោះសត្រូវដែលមកយាយីទៀត ៗ នៅឯទីលានពិធីបូជា មានការនិយាយរឿងព្រេង ស្តាប់គេដេញពិណ ធ្វើហោម ៗ មួយឆ្នាំ សេះត្រឡប់មកវិញ ទើបមានធ្វើពិធីសម្លាប់សត្វបូជា, មានធ្វើពិធី

ទីក្សា (ពិធីសារពើ) ១២ ថ្ងៃ, មានការរស់វេទី តមកគេ
ធ្វើពិធី ឧបនិស័ទ ១២ ថ្ងៃ, ពិធីសោម ៣ ថ្ងៃ, ពិធីឧបនិ-
ស័ទនិងថ្ងៃមួយនៃពិធីនេះ ត្រូវធ្វើឲ្យត្រឹមត្រូវតាមអគ្និស្តោមៈ
(ពិធីសូត្រសរសើរព្រះអគ្និ) ។

រីឯ ថ្ងៃទីពីរជាពិធីធំបំផុត គឺថ្ងៃនោះ គេយកសេះញ៉
ទៅបង្ហាញសេះ (អស្វមេធ:) គេយកសេះនេះទៅទឹមរថចម្បាំង
វិចិត្រដោយមាស ហើយគេនាំទៅកាន់ត្រពាំងមួយ គេយក
ប្រេងទៅលាបសក់និងកន្ទុយសេះ ហើយយកគជ់ ១០១ ទៅ
បិទភ្ជាប់ ៗ ពេលនេះ ជាពិធីសម្លាប់សត្វបូជាធំ មានសត្វ
ផ្សេង ៗ ចំនួន ៦០៩ គេយកទៅប្រជុំហើយចងបង្គោលនៅ
ជុំវិញសេះ (អស្វមេធ:) ហើយគេសម្លាប់បសុសត្វទាំងនោះ
ខ្លះគេលែងចោលទៅវិញ ទើបគេធ្វើពិធីយជ្ញ: គឺសម្លាប់សេះ
(អស្វមេធ:) នោះ ដោយការបន្ទប់មិនឲ្យដកដង្ហើមរួច ៗ ព្រះ
ជាយាទាំងឡាយត្រូវដើរជុំវិញខ្មោចសេះនោះ ឯព្រះអគ្គជាយា

ត្រូវទៅផ្ទុំនៅក្បែរសេះ សំដែងជាការហាក់ដូចជាបង្កាត់កូន ។ ព្រាហ្មណ៍អ្នកបួសនិងស្ត្រីដទៃទៀត និយាយគ្នាលេងដោយពាក្យឥតខ្លឹមសារអាសអាភាស តមកមានការសន្ទនាគ្នាដោយប្រស្នា ឬ ពាក្យបណ្ដៅរវាងហោត្រនិងអ្នកធ្វើពិធី តមកមានធ្វើបូជាពោះវៀន ? (Epiploon) ទឹករលាម, ដុំសាច់សេះទាំងសក្ដិទៀត , ព្រមទាំងបូជាលោហិតទៀត ។

រីឯថ្ងៃទី ៣ មានធ្វើពិធីហៅថា អតិរាត្រៈ បញ្ចប់ដោយពិធី អវភ្ឫថ (Avabhrtha) គឺពិធីស្នានៈ (ងូតទឹក) មានអ្នកទោសឧក្រិដ្ឋនិងអ្នកខេសាចចូលផង ។ ដើម្បីសម្រេចមានការសម្លាប់គោញីអា ២១ ទៀត ការបែករង្វាន់ទានទៅដល់អ្នកបួសធ្វើពិធីអស្វមេធៈទាំង ៣ ថ្ងៃ ហើយបញ្ចប់ដោយការឲ្យដាក់រាជអគ្គជាយាទាំង ៤ នាក់ ព្រមទាំងបរិវារដល់ព្រាហ្មណ៍អ្នកបួស ។

x

x x

គ្រួសារ.– ព្រំដែនសកម្មភាពនៃសង្គមឥណ្ឌាពីបុរាណ សម្រាប់ជនជាតិកណ្ដាល មិនតាំងនៅឆ្ងាយពីវិស័យស្រែចំការខ្លួនទេ ៗ ជនម្នាក់ ៗ ដែលមានពូជពង្សជាមួយគ្នា តែងតែរស់នៅជាមួយគ្នាតាមច្បាប់ ក្រុមនីមួយ ៗ សុទ្ធតែជាញាតិសន្ដាន ៗ ជន្មន (Janman) គឺបិតាជាមេខ្សែស្រឡាយតំណពូជពង្សពីមួយទៅមួយ ជាប់ទាក់ទងគ្នាជិត ហើយរស់នៅក្នុងគ្រាមជាមួយគ្នា ៗ

ពួកអាយ៌នដែលជាអ្នកលុកលុយ ជាជនពនេចរ មិនមានគ្រាមជួបជុំគ្រាន់ជាអ្នកកំណើតស្រុកទេ តែមានកូនចៅតពូជពង្សកាន់ប្រពៃណីគ្រួសារជាប់តាមនាទីខ្លួន ហើយការពារបូរណភាពត្រកូលខ្លួនចុះរហូតមក ព្រោះជាករណីយកិច្ចសង្គមរបស់ខ្លួនដោយពិសេស ៗ គម្ពីរវេទជាជំនួយជួយរក្សាប្រពៃណីដែលខ្លួនត្រូវបារម្ភខ្លាចសាបសូន្យទៅយ៉ាងខ្លាំងបំផុត ៗ រីឯសង្គមទ្រាវិឌ ដែលត្រូវគេលុកលុយផ្សងទៅវិញ មានទី

ស្ថាននៅជាប់នឹងជំនឿ មានស្រេចការតាមជនបទ ហើយមាន ទាំងគ្រឿងថែមទៀតផង ។ ដូច្នេះ ការកិច្ចគ្រួសារ នៃជនទ្រាវីឌ ឋិតថេរនៅបានតាមកាលនៃប្រវត្តិសាស្ត្រ ដូចការបូជា (Cultes) ក្នុងកម្ពុជាដើម ហើយដឹកនាំឲ្យអាយ័នកាន់តាមខ្លួនខ្លះផង ។ លក្ខណៈតាមនិងជំនឿនេះហើយ ដែលបញ្ជាក់ការណ៍យខ្ញុំ ប្រពៃណីនៃជនជាតិឥណ្ឌា ឲ្យឃើញច្បាស់លាស់ ក្នុង កាលឥឡូវនេះ ។

គ្រួសារនីមួយៗ នៃជនឥណ្ឌាសព្វថ្ងៃនេះ ឋិតនៅក្នុង មជ្ឈដ្ឋាននៃពួកពីរ ដែលមានមូលដ្ឋានផ្សេងគ្នា ។ មត្តេយ្យ-ភានិងពហុបតិភាព នៅមានឋិតថេរក្នុងវត្តជាតិទ្រាវីឌបុរាណ, ដំណើល ឬ អនុស្សាវរីយ៍ ក៏នៅមានឋិតថេរដែរ ។ ឯអាយ័ន ផ្សេងទៅវិញ មានតែឲ្យស្រឡាយជាប់គ្នាមក ដែលគេហៅថា ជន្ម គឺដើមកំណើតពូជតាមឧបាទរូប ហើយ ដឹកនាំឲ្យអនុជនកាន់តាមក្រោយតរហូតមក ។

គ្រួសារគោយ័ន មានសមាសភាពក្មួយនិងក្មួយជីដូនមួយផង តាមខ្លួនទៅដែលគឺ ជន ជន្ទន រួមខ្សែស្រឡាយច្រើនបានទៅជាគោត្រមួយ ហើយក៏តបានទៅជាកុលសម្ពន្ធមួយមានសភាគ្រោមមួយ ហៅថា បញ្ចូយ័គ ។ ព្រឹត្តិការណ៍ជនណាដែលចាស់បរមបុរាណនោះ គឺក្រុមសន្តិមតូច ឬ ធំដែលមានខ្សែស្រឡាយចាក់ចង់គ្នា ដែលហៅថា "គោត្រ" ។ រឯលក្ខណៈពិសេសនៃគោត្រនេះ ប៉ុន្តែមិនមានគោរពក្តិសាច់ញាតិដែលមានឈាមជាមួយគ្នាប៉ុណ្ណោះទេ គឺគេនគាមក្រុមខ្លួនដែលប្រតិបត្តិសាសនាជាមួយគ្នាទៀតផង ដែលហៅថាញាតិសន្តាន គឺហៅចំពោះតែអ្នកដែលគោរពបូជាបុព្វបុរសជាមួយគ្នាតែប៉ុណ្ណោះ ។ សេចក្តីនេះបញ្ជាក់ឲ្យឃើញច្បាស់ថា សន្តិមណាជាធម្មជាតិសន្តិមច្រើនជាងពួជនៃញាតិសន្តាន ។ ប៉ុន្តែដែលមិនមានកូនប្រុស ដើម្បីរក្សាគោរកិច្ច នៃគ្រួសារឲ្យបើកជេរទៅបានទេ, ត្រូវតែយកប្រពន្ធខ្លួនទៅឲ្យប្រុសដទៃទៀត

ដើម្បីឲ្យបានកូនប្រុសទុកជាមេគ្រួសារតទៅ ។

បិតា ជីតា ឬ បុព្វបុរសជាមេគ្រួសារ ហៅថា "បតិ" ដូចប្រពៃណីខ្មែរយើងថាប្តី ជាមេគ្រួសារក្នុងផ្ទះនីមួយ ៗ នេះព្រោះតែយើងកាន់តាមទំនៀមឥណ្ឌា តាំងពីបុរាណរៀងមក ។ ឯមេក្រុម ដូចខ្មែរយើងហៅថា "មេភូមិ" ហៅថា វិស្បតិ (វិឝ ពួក, ក្រុម + បតិ មេ, ម្ចាស់) ។ ឯវិស្បតិនេះ ត្រូវជ្រើសតាំងឲ្យទៅជាសេនាបតី ក្នុងកុលសម្ពន្ធខ្ទង់ទៀតផង ហើយឲ្យឈ្មោះ "រាជ=ស្តេច" ដើម្បីគ្រប់គ្រងកុលសម្ពន្ធខ្ទង់ឲ្យមានរបៀបរៀបរយ (សំ. Rājati=) អាវែស្តៈ Rāzayeiti ។ អំណាចដែលត្រូវជ្រើសតាំង រាជ នេះ ត្រូវសភានៃកុលសម្ពន្ធ ជ្រើសតាំង ដូចនេះ សភានេះ តមក មានន័យច្បាស់ហោស់ដូច (ផ្ទះសភាយើងក្នុងបច្ចុប្បន្នកាលនេះ ។ នេះហើយជាវិជ្ជាបុរាណដើម តមកកើតបានទៅជាស្ថាប័នល្អមួយក្នុងអនាគតឡើង ។

X

X X

ការបូជាក្នុងគ្រួសារ (Cultes familials) .— អគ្គិជា ជើងក្រានកណ្ដាល ជើងក្រានជាឯកភាព ជើងក្រានជាការ-កិច្ចធំបំផុតនៃគ្រួសារណា ៗ ប្រពៃណីគោរពអគ្គិនេះ បាន ទៅពីកាលតមក តាមកាលនៃប្រវត្តិសាស្ត្ររបស់លទ្ធិហិណ្ឌូ ជាលទ្ធិសាសនានៃអារយ៉ន មុនប្រវត្តិសាស្ត្រ ព្រោះគេបាន ឃើញមានក្រានទុកក្នុងគម្ពីរវេទ ៗ

គ្រួសារណាមួយ ៗ ត្រូវតែមានជើងក្រានគឺ អគ្គិ មួយ, គេទុក អគ្គិ នេះ ជាម្ចាស់នៃគេហដ្ឋានដែលហៅថា “គ្ឫហបត្យ” បើជាម្ចាស់នៃគ្រាមហៅថា “វិត្យៈប” ដូច ជាបិតាដែលជាមេគ្រួសារដូច្នេះដែរ តាមរចនាសម្ព័ន្ធគួបផ្សំ នៃគោត្រនោះ ៗ ។ អគ្គិនេះ កាលដើមឡើយ គេដុតបំពក់ ទុកនៅក្នុងជ័រនៃផ្ទះខាងចេរ ដើម្បីការពារសត្វសាហាវយង់ យង់ ឬរក្សាអ្នកគង្វាលខិនហ្វុងសត្វពាហនៈ ដែលហៅថា “គោបៈ” ទៀមានការតាំងនៅដោយប្រពៃណីប៉ុណ្ណោះទេ តែ

តមក អគ្គិនេះ មានន័យទៅជាភ្លើងពហុរូប គឺមិនមែនផុត
បំពក់ចំពោះតែត្រឹមកិច្ចការដើនក្រានទេ ដោយពិត គឺដុតដើម្បី
បំភ្លឺលោក ដូច្នេះអគ្គិនេះ គេទុកជា "ទេពអគ្គិ" គឺ "វិទ្យុត=
ផ្លេកបន្ទោរ" ឬ "អាទិត្យ=ថ្ងៃ" ។ វិទ្យុត=(ផ្លេកបន្ទោរ)
មានកំណាចខ្លាំងណាស់ តែជាមិត្រនឹងមនុស្សលោក សម្រាប់
បំផ្លាញសត្រូវ ធ្វើឲ្យមានកំដៅឲ្យភ្លឺគ្នាក្នុងលោករស់នៅបាន
តមកទៀតកើតទៅជាភ្លើងចិត្ត ហៅថា "ទេវៈ" ដែលកំពុង
តែនេះបំភ្លឺលោកសព្វថ្ងៃនេះ ។ ទេវៈនេះខ្ពង់ខ្ពស់ជាងមនុស្ស
ដូចជាឋានសួគ៌ ខ្ពង់ខ្ពស់ជាងឋានមនុស្សលោកដូច្នោះដែរ តែ
មិនមានអ្វីជាគ្រឿងដែលមនុស្សលោកឲ្យប្រសើរជាជាងដើនក្រាន
ដែលចំអិនអាហារ ឬ ធ្វើពិធីបូជា ពុំនោះជាអធិបតីនៃអំពើគ្រប់
ជំពូក គន្ធជីវិតពមនុស្សនេះទេ ។ ឯអគ្គិនេះ មិនមែនដូចទឹក
ដែលហូរចេញមកពីពពកដូច "ខៃ្យទឹក" (Apam nabhat) ទេ
គឺកើតចេញមកពីការត្បុកឈើពីរនួតពីរ ដែលហៅថា "អរណី"

បើអ្នកណាចេះរក្សាភ្លើងនេះទុកដោយប្រយ័ត្នមិនឲ្យរលត់ទៅវិញ បាន គឺនៅតែឆេះជានិច្ចដរាបទៅ អ្នកនោះគេទុកជាបុគ្គល មានភក្តិសំខាន់ប្រសើរណាស់ ។ បព្វជិតបុគ្គលណាជាជន ហិណ្ឌូ ឯកន ដែលជាអ្នករក្សាភ្លើងជើងក្រានេះ ហៅថា អថវ៌ន ប្រែថា "អ្នកបួសរក្សាភ្លើង" ។

មួយទៀតការរក្សាភ្លើងទុកបន្តរបតក្តី ការរក្សាវិញ្ញាណ-ហិតតំបព្វបុរសតមកក្តី មិនមែនទុកត្រឹមតែនាមនិយមរូបទេ គឺត្រូវពិតប្រាកដមែនទែន ។ ភ្លើងជើងក្រានេះទុកជា "បុព្វបុរស" គឺជាបិតា ជីតា ឬជីតាទួតលួតណា ដូចជាជនជាតិចិនរក្សា "កុងម៉ា" ឬជនជាតិក្រិករក្សា "ត្រិបិតុរ" (Tripitores) ពុំនោះដូចជាជនជាតិហិណ្ឌូបុរាណរក្សា "សបិណ្ឌបិតរស" (Sapinda Pitares) ដែរ ហើយមានចំណាប់តាំងគ្រួសារផង ។ ភ្លើងដែលឆេះគង់ហើយបញ្ចេញអណ្តាតភ្លឺ ៗ ក៏សន្មតទុក ជាជីវិតបុព្វបុរសគឺបិតាជីតាទួតលួតណា ដែលមានលក្ខណៈ

សក្តិសិទ្ធិរស់រវើកដល់មកសព្វថ្ងៃនេះ ។ ឯគ្រឿងពលីជាអាហារបូជាដល់បុព្វបុរស ដែលស្លាប់ទៅនោះ ត្រូវតែដុតក្នុងភ្លើងផង ទើបបានដល់ទៅអ្នកដែលស្លាប់ ។

ដោយអាស្រ័យវត្ថុ គឺភ្លើងចង្ក្រានដែលគេទុកជាខ្សែលោហិតនេះ បានជាពិភពលោកនេះតែកើតបន្តៗគ្នា ពីមួយទៅមួយស្មើជាដរាបទៅ ហើយភ្លើងនេះនៅក្នុងប្រជាជាតិបានជាអាកាសគ្នី, អាកាសគ្នីនេះទុកជាបិតា ហៅថា ទ្យូសិបិតរ (Dyeus-pitar) ជាគោលជំនឿនៃជនជាតិហិណ្ឌូអារ្យ័ន ដូចជាប្រពៃណីក្រិក-ឡាតាំងថា (Zeus pater = Jupiter) ។ ជំនឿទាំងនេះ បង្កើតឲ្យកើតជាលោកវិទ្យា (Cosmologie) និងទេវកថាវិទ្យា (Mythologie) ដែលបណ្ដុះបណ្ដាលឲ្យមានពិធីបូជាគ្រួសារដែលជាកិច្ចនិងខានធ្វើពុំបានឡើយ ។ ឯការចាក់ទឹកទៅកាន់ទេវលោក ត្រូវធ្វើទៅតាមភ្លើង យកភ្លើងជាស្ពាន ដូចជាការចាក់ទឹកទៅកាន់បុព្វបុរសដូច្នោះដែរ ។

បណ្ដាភ្លើងទាំងអស់ ភ្លើងអគ្គិនេះ ទុកជាភ្លើងឧត្តមបំផុត ។ ឯម្ចាស់គ្រួសារ ជាអ្នកធ្វើពិធីយជ្ញៈ ។ កាតព្វកិច្ចខាងគោរ-កិច្ចនេះ មានក្រោទុកដោយពិសេស ក្នុងក្បួនពិធីបូជាប្រចាំគេហដ្ឋាន ហៅថា គ្ឫហ្យសូត្រ ។ គម្ពីរគ្ឫហ្យសូត្រនេះ ជាគម្ពីរឯក ឬធំបំផុតសម្រាប់គ្រួសារ ។ មានគម្ពីរមួយទៀតហៅថា "ស្រៅតសូត្រ" ជាគម្ពីរនិយាយពីការធ្វើពិធីបូជាតាមការបានស្ដាប់មក ដែលហៅថា (ស្រុតិ çruti) ។ លោកនៅវែរ Krouer សរសេរថា ភ្លើងអគ្គិទុកជាភ្លើងទីមួយ ដែលម្ចាស់គេហដ្ឋានត្រូវធ្វើពិធី ហើយតមកមានភ្លើង ២ ទៀតទៅជា ៣ សម្រាប់ពិធីសោមៈ ភ្លើងមួយត្រូវដាក់លើអាសនៈទិសខាងកើត ហៅថា "អាហវនីយ" មានកន្លួនច្រើន មួយទៀតមានទ្រង់ទ្រាយជាអឌ្ឍចន្ទ្រ ត្រូវដាក់នៅលើអាសនៈទិសខាងត្បូងពីអាសនៈប្រចាំគេហដ្ឋាន ដែលហៅថា អន្វាហារ្យប-ចនៈ ឬទក្សិណាគ្និ ។ ភ្លើងទាំងពីរនេះ ត្រូវដុតបន្តមកពី

ភ្លើងជើងក្រានដែលជាភ្លើងទីមួយ ៗ កាសុខៈអគ្គិនៃគហបតី

នេះ ហៅថា "វេទិកា" (Autel) មានទំហំតូច គឺជាភ្នក់គំនរ

ខ្ពស់ (សមិធ) ឬ ស្មៅកុសៈ មានទ្រង់ទ្រាយបួនជ្រុងទ្រ.

វែង ហើយជ្រុងទាំងបួនរួបតូចមកបន្តិច ជាទីសម្រាប់ដាក់

គ្រឿងពលីដូច ទឹកដោះ ទឹកដោះខាប់ គ្រាប់ពូជ សាច់ សុរា ៗ

នៅលើវេទីនេះហើយ ដែលទេវតាមកដល់នៅអាស្រ័យចាំទទួល

យកយញ្ញៈ ៗ វេទី ពោះធំក្តី ឬ ពោះតូចក្តី ជាការបូជា

ទេ តែពិធីបូជានោះ ជាកិច្ចការចាំបាច់បំផុត ហើយមានការ

រញ៉ិករញ៉ូកច្រើនបំផុត ៗ ម្ចាស់ផ្ទះត្រូវបំពេញកាតព្វកិច្ចខាង

ការកិច្ចនេះ តាំងពីព្រឹក រហូតទៅដល់ល្ងាច ៗ វេលា

សន្ធ្យាព្រឹក ម្ចាស់ផ្ទះមានកិច្ចត្រូវប្រតិបត្តិច្រើនប្រការ ដូច

ត្រូវទៅមុជទឹកហូរ (ទឹកស្ទឹង ?) ជម្រះធ្មេញ តែងសក់ ហាក់

ដកដង្ហើមខ្យល់ចេញចូល សូត្រគាថាគាយត្រី(១) ជាមន្ត្រ

សក្តិសិទ្ធិថា :

ឧម៌ ភូរ ភុវ: ស្វ:

តត៌ សវិតុរ៌ វរេណ្យម៌

ភគោ៌ ទេវស្យ ធីមហី

ធិយោ យោ ន: ប្រចោទយាត៑ ។

ក្នុងការបំពេញកិច្ចបូជានេះ មានអត្ថបទគម្ពីរវេទផ្សេងទៀតច្រើនណាស់ ។ គហបត ម្ចាស់ផ្ទះត្រូវធ្វើមហាយជ្ញ: គឺបូជាទេវតាភូត, បិត្រ, នរ ។ ការបូជារបស់ទាំងនេះ ជាការបំពេញបដិសណ្ឋារកិច្ចចំពោះទេវតា ឯការបូជាព្រហ្មន៍ ត្រូវ

---

១ ក– ព្យាង្គប្រកបដោយកំពូលពុកាពកា ឧម:; ខ- តាមនៃលោកទាំង៣ជាន់ខ្ពស់គឺ ដី អាកាស ឋានសួគ៌; គ-៣ឃ្លាទាំង ៣ ជាន់ នេះ ដកស្រង់ចេញមកពីឫគ្វេទ (111.62, 10) មានព្យាង្គប្រាំបីគឺ «ពន្លឺដែលយើងតប្បីប្រាជ្ញា ជាភាពនៃទេវតាសាវិត្រ យើងសូមឱ្យបានសប្បាយភាពនោះ ព្រះសវិត្រនោះ គួរដាស់តឿនចិត្តយើង» ។

ធ្វើដោយការអានគាថាវេទ ជាកិច្ចគោរពចំពោះគ្រូ ៗ តមក
ទៀត ម្ចាស់ផ្ទះ ត្រូវគោរពទេវរូបប្រចាំផ្ទះ (អាយតនៈ) គឺ
រូបដែលជានិមិត្តរូបនៃទេវតា ដូចវិស្ណុ សិវ ទុគ៌ា គណេស សូរ្យ
ជាដើម ៗ រាល់ព្រឹករាល់ល្ងាច ត្រូវធ្វើពិធីអគ្និហោត្រ គឺការ
បូជាភ្លើងតាំងពីថ្ងៃរះ ៗ ពេលបាយថ្ងៃត្រង់ ត្រូវបោះដុំ
បាយទៅក្នុងភ្លើង ទុកជាការបូជាទេវតាទាំងឡាយ (វៃស្វទេវ)
រួចហើយយកដុំបាយតូច ៗ ទៅដាក់នៅខាងក្នុងគេហដ្ឋាន និង
ខាងក្រៅគេហដ្ឋាន ជាកិច្ចបូជាចំពោះទេវតា ភូតបិសាច និង
សត្វតិរច្ឆាន ទើបបានពួកបុរស ៗ ចាប់បរិភោគអាហារ តន្ទ្រៃ
វៃតខ្លួន ស្ត្រី ៗ បំរើ បំរើរួចហើយ ទើបបរិភោគខ្លួនឯង
ជាខាងក្រោយ ៗ វេលាសន្ធ្យាល្ងាច ពេលព្រះអាទិត្យ
អស្ដង្គត ត្រូវប្រតិបត្តិជាថ្មីទៀត ៗ

ទិសម្នាមាតាការជីវិតនៃជនវណ្ណៈម្នាក់ ៗ .- ជនវណ្ណៈ
ម្នាក់ ៗ មានកិច្ចត្រូវធ្វើពិធីបរិល ៦០ បេការ ហៅថា សំស្ការ

ប្រែថា «ធ្វើឲ្យសក្តិសិទ្ធិ ឬសិទ្ធិ» គឺធ្វើឲ្យបរិសុទ្ធ ឲ្យ
បានកូន បើប្រុសឲ្យបានជា គ្រូហបតិ បើស្រីឲ្យមានប្តី ដោយ
សង្ខេប ពិធីនេះ មាន ១២ ប្រការ គឺ

(១) ពិធីស្តូ.បព្រោះព្រំគភ៌ ហៅថា «គភ៌លម្ភនៈ ឬ
គភ៌ាធានៈ» ពិធីនេះ ត្រូវធ្វើក្រោយមង្គលការ ៤ ថ្ងៃ ជា
ពិធីការពារគេបង្គល ហើយឲ្យបានកូនប្រុស ធ្វើដូចគ្នានឹងពិធី
ចម្រើនលោកខ្មែរយើង ។ ក្នុងពិធីនេះ ត្រូវប្តីយកស្បូវកំទៅឲ្យ
ប៉ះពាល់ក្លិនយោនិ ពិធីគួរហូតបក រួចហើយសូត្រមន្តសូធ្វថា
«សូមព្រះវិស្ណុរៀបចំគភ៌ឲ្យ» «សូមព្រះបង្កើតលោក កជារូប
កូនឡើង» «សូមព្រះបជាបតីជារក្សាព្រោះព្រំឲ្យ» «សូមព្រះ
បង្កើតលោកញ៉ាំងកូនឲ្យកើតក្នុងគភ៌» ។ ពិធីនេះនៅមាន
ក្បួនពាបបកដល់សព្វថ្ងៃនេះ តែច្រើនតែក្នុងពួកហិណ្ឌូដែលជា
គ្រូបដិបន្ន ។

ជនហិណ្ឌូច្រើនចង់ស្រឡាញ់កូនប្រុស បើមានកូនស្រី

គេទុកជាជាអភ័ព្វ ក្នុងគម្ពីរនិយាយថា "មានតែកូនប្រុសទេ ដែលអាចរៀបចំពិធីបុណ្យសពជូនពុក ហើយអាចនាំឲ្យទៅកើតឋានសួគ៌បាន" ។ កូនប្រុសហៅថា "បុត្រ" មានន័យ "អ្នកជួយដោះទុក្ខដល់ពុកមិនឲ្យធ្លាក់ទៅនរក" ។

២- ពិធីមន្តសុំឲ្យបានកូនប្រុស ហៅថា "បុំសវន" ។ ពិធីនេះ ត្រូវធ្វើក្នុងពេលដែលមានគភ៌ ៣ ខែហើយ ត្រូវបន់ ៣ ដងក្នុងមួយថ្ងៃ ដើម្បីឲ្យបានកូនប្រុស ។ ក្នុងពិធី គេយក ម្សៅព្រោះព្រំចុងប្រមុះខាងស្តាំនៃភរិយាដោយបែកមិនគ្រោធ ឲ្យផឹកទឹកដោះ ហើយសួរថាផឹកអ្វី ? ភរិយាឆ្លើយថា "បង្កើតកូនប្រុស" ពិធីនេះហៅថា "អនវលោភន" ក៏បាន ។

៣- ពិធីមន្តញែកសក់ ហៅថា "សីមន្តោន្នយន:" ។ ពិធីនេះ ត្រូវធ្វើដោយចាក់បន្តក់ប្រេងក្រអូបទៅលើក្បាលប្រពន្ធ ហើយញែកសក់ពីប្រជុំចិញ្ចើមមកឲ្យទៅត្រង់កណ្តាលក្បាលបែប ដូចជាយកកុដដោយដៃឧទុម្ពរ មួយទៀតមានន័យថា សក់នៅ

ទុកជាសូត្រគុណៈ ៣ សពែស ហើយយកសក់ដែលទុកជាសោ
គុណៈទៅដាក់ត្រង់ប្រមុំចិញ្ចើម ៣ ដង ម្ដង ៗ ត្រូវសូត្រគាថា
វេទថា ភុរ៍ ភុវ៍ និង ស្វ៍ ព្រមទាំងវេបនៈថា "ឱម"
ជាពាក្យនមស្ការគ្រឹមូក៏ទេវតាផង ។ តាមវិធីនេះ គេជឿថា
ដេញ[illegible]ចេញ ហើយបញ្ចូលគតិក្នុងតក់ប្រពន្ធដើម្បី
ការពារអន្តរាយដល់កូនដែលមិនទាន់កើត ។

៤- ពិធីមង្គលតាប់កំណើត ហៅថា "ជាតកម៌ន" ។
ពិធីនេះ ត្រូវធ្វើក្រោយពេលដែលកូនកើតហើយ មុនកាត់
ទងសុក ត្រូវឪពុកយកស្លាបព្រាមាស ដែលដាក់ពេញដោយ
ទឹកឃ្មុំ និងទឹកដោះគោខាប់ ទៅដាក់និងបបូរមាត់កូន ហើយ
សូត្របន់ស្រន់តាមគម្ពីរវេទថា "ឱព្រះមានអាយុវែង ! សូម
ឲ្យកូននេះមានអាយុ ១០០ ឆ្នាំនៅនាលោកនេះ ដោយ
ការគោរពទេវតា" ក្រោយពីការដាក់បបូរមាត់ ត្រូវដាក់ត្រ-
ចៀកកូនទៀត ហើយសូត្រថា "សូមព្រះសាវិត្រី សូមព្រះ

សរស្វតី សូមព្រះអគ្គិន ប្រសិទ្ធិឲ្យកូនមានប្រាជ្ញាជ្រៅឈ្លាស តទៅទីបំផុត រីកសាកូន ហើយសូត្រថា "ចូរឯងមាំមួនដូចថ្ម មុតដូចពូថៅ បរិសុទ្ធដូចមាស ចូរឯងរស់នៅ ១០០ ឆ្នាំ សូមព្រះឥន្ទ្រប្រគល់ឲ្យនូវកំណាប់ទ្រព្យដ៏ប្រសើរដល់ឯង" ។

៥- ពិធីបន្តុលឲ្យឈ្មោះហៅថា "នាមករណ៍" ។

ពិធីនេះ មានទូទៅពេញប្រទេសឥណ្ឌា គេធ្វើពេលក្រោយកូនកើត ១០ ថ្ងៃ ឬ ១២ ថ្ងៃ ។ គ្រួសារដែលមានកូនកើតបាន ១០ ថ្ងៃ គេទុកជាគ្រួសារមិនស្អាត ។ មុនធ្វើពិធីឲ្យឈ្មោះ ត្រូវធ្វើពិធីលាងបាបមួយមុនសិនគឺ "ម្ដាយត្រូវមុជទឹកឲ្យស្អាត ជញ្ជាំងបន្ទប់ត្រូវលាបអាចម៍គោ ឯបន្ទប់មុជទឹកក៏ត្រូវសំអាតឲ្យមត់ចត់ណាស់ដែរ ត្រូវបូជាផ្កាមានពណ៌ក្រហមលាបម្សៅ ហើយដុតចង្កៀងឲ្យភ្លឺ ត្រូវមានគ្រឿងបូជាដទៃទៀតដូចជា ប្រាក់ អាវទ្រនាប់ និង សំពត់ លុះបំពេញកិច្ចការទាំងនេះបរិបូណ៌ហើយ ទើបរាប់ថា គ្រួសារនោះបានធ្វើ

ឲ្យបរិសុទ្ធហើយ ។

ជនហិណ្ឌូយកចិត្តទុកដាក់ក្នុងការឲ្យនាមនេះណាស់ ។

គ្រូហោរាគន់គូរមើលផតាកសី ជ្រើសនាមឲ្យបាន ៣ ឬ ៤ ហើយឲ្យឪពុកជាអ្នករើសយកឈ្មោះណាមួយ ។ អក-ខ្លះហិណ្ឌូមានហោរជំនាញគន់គូរយូរខែណាស់ ឯពិធីឲ្យនាមក៏ត្រូវធ្វើនៅថ្ងៃក្រោយទៀត ។ បើនាមតាមជាតផតា

...បនាមដែលគេឲ្យក្នុងពេលកើត ១០ ថ្ងៃនោះទេ កូនប្រើយកនាមទៅតាមជាតផតាវិញ ។ នាមត្រូវរើសយកពាក្យ...ពីដល់នក្ខត្តឫក្ស ។ ឯនាមពិតមែននៃកូននោះ មិនមែននាមដែលគេឲ្យក្នុងថ្ងៃធ្វើពិធីនាមករណៈ ឬ នាមតាមជាតផតាទេ គឺនាមសម្ងាត់ដែលគ្រូបាធ្យាយខ្សឹបឲ្យ នាមនេះទើបជានាមមែនទែន ។ បើជនណាមួយគាបដឹងនាមនេះបាន គេជឿថាមានអំណាចទៅលើអ្នកនោះណាស់ ។

កូនប្រុសត្រូវឲ្យនាមតាមឈ្មោះទេវតាប្រុស ដូចជាក្រុប,

កម, គោបាល, គណេគ, សង្ករ ។ល។ ឬនាមទៅតា ប្រុសពីររួមគ្នា ហរិ·ហរ គិរ·កម គោបាល·ក្ឫស្ណ លក្ស្មី–នារាយណ៍ ឬក៏គេនាំឱ្យឈ្មោះថា ទាស ជាខ្ញុំទេពតា ដូច ហរិ·ទាសិ កាលិ·ទាសិ គោបាល·ទាសិ ទុគ៌ា·ទាសិ ឬ នាមក្នុងមហាកាព្យ: អជ៌ុន ភីម ហនុមាណ ។ល។

កូនស្រីគេឱ្យនាមតាមនាមទេពតាស្រី: សរស្វតី បវ៌តី លក្ស្មី ឬឧមា ស៊ីតា ពេជ្រ ឬក៏មោះ គុណសម្បត្តិ ដូច កមល ឬ កមលា, កុសុម, មុក្តិ, (គុជ) វិមល, សុន្ទរី, ប្រេម, មោហិនី (ល្អ) វសន្តិ គង្គា យមុនា គោទាវរី កវេរី ។ល។

៦– ពិធីមង្គលនាំចេញទៅក្រៅហៅថា "និក្រមណ" ។ ពិធីនេះ មិនធំដុំប៉ុន្មានទេ ត្រូវធ្វើក្នុងខែទី ៤ ក្រោយខែកំណើត ដែលកូនកើត គឺត្រូវម្តាយបីកូននាំចេញទៅខាងក្រៅ ទៅនៅកណ្តាលវាល តាមក្រោយបន្ត ត្រូវបង្ហាញកូនទៅព្រះ

គាថាហើយសូត្រថា "ក្តុកជាពន្លឺ ជាមង្គលដល់ទេវតា ដែលរះឡើងពីទិសខាងកើត សូមឲ្យកូនយើងរស់នៅបានអាយុ ១០០ ឆ្នាំ" យើងសូមពរថា : : ស្តាប់ និយាយ មានសេរី ដោយអំណាចទេវតាអស់កាល ១០០ ឆ្នាំ ។ តពីនេះទៅទៀត មាតាបិតាយកកូនទៅកាន់ទេវាល័យក្នុងភូមិ ហើយបន់សូមឲ្យកូនបានល្អ ។

៧- ពិធីមង្គលឲ្យអាហារហៅថា "អន្នប្រកន" ។ ពិធីនេះ ត្រូវធ្វើក្រោយពេលដែលកូនកើតហើយបាន ៦ ខែ ត្រូវប្រជុំញាតិមិត្រឲ្យមកជួបជុំគ្នា ហើយឲ្យកូនបរិភោគអាហាររឹងជាបឋម ។ ព្រាហ្មណ៍សូត្រគាថាវេទឲ្យពរ តពីកូនស៊ីមក ត្រូវតែឲ្យបរិភោគអាហារ ។

៨- ពិធីមង្គលកោរសក់ហៅថា "កេសូវ" ។ ពិធីនេះ សំខាន់ណាស់ដែរ ។ ជនហិណ្ឌូយកចិត្តទុកដាក់ក្នុងពិធីនេះណាស់តាមលទ្ធិសាសនាដោយប្រកាន់ជឿថា "សក្ក-

សិទ្ធិក្នុងការលាងខ្លួននិងចិត្តឲ្យស្អាត” ដូចប្រពៃណីកោរសក់ព្រៃ ឬការសក់ខ្មែរយើងផង ៗ ពិធីកោរសក់ខ្មែរយើងក៏ជាមង្គលមួយធំណាស់ដែរ ៗ

៩– ពិធីមង្គលកាត់សក់ហៅថា “កេតាន្ត” ។ ពិធីទាំងពីរគឺកោរសក់និងកាត់សក់នេះ មិនប្លែកគ្នាប៉ុន្មានទេ តែពួកព្រាហ្មណ៍ពេញចិត្តនឹងធ្វើណាស់ ៗ កាលបើកូនអាយុបាន ៣ ឆ្នាំហើយ មាតាបិតាតែងធ្វើពិធីនេះឲ្យកូន ឬជួនកាលកូនដល់អាយុ ៧ ឬ ៨ ឆ្នាំ ទើបធ្វើក៏មានដែរ ៗ គម្ពីរកេត្ត-លាយន: និយាយថា ក្នុងពិធីនេះ ឪពុកត្រូវយកកូនទៅដាក់លើភ្លៅម្ដាយ ដែលអង្គុយនៅខាងលិចភ្លើងក្រានអគ្គិ ឪពុកត្រូវឈរខាងត្បូងម្ដាយ កាន់ស្មៅកុស: ២១ ដើម ហើយប្រោះព្រំក្បាលកូន ដោយទឹកក្ដៅលាយទឹកដោះខ្លាញ់ និងទឹកដោះគោ ៣ ដង ហើយយកស្មៅកុស: ទៅញាត់ខាងស្ដាំសក់កូន ៧ ដង ស្មូត្រថា “ឱកុស: វិត្ថ:អើយ ! សូមរក្សាកូននេះ” រួច

កាត់សក់បន្តិចហុចទៅម្ដាយ ព្រមទាំងសូត្រគាថាផង ទុកបូ-ឆា (កំបោយ) មួយ នៅលើក្បាលកូន ឬ តាមប្រពៃណីខ្លះត្រូវទុកបូឆា ៣-៤-៥ សរសៃ ។

១១-ពិធីបន្តួលនាំកូនឲ្យទៅរៀនហៅថា "ឧបនយន" ។ ពិធីនេះ ជាពិធីសំខាន់បំផុតមួយ គេហៅពិធីនេះថាជា "ពិធីបញ្ចូលខ្សែស្រឡាយ" ក៏បាន ព្រោះពិធីនេះត្រូវធ្វើដើម្បីឲ្យកូនបានជាប់ខ្សែស្រឡាយជាព្រាហ្មណ៍ ។ ពួកព្រាហ្មណ៍ខ្លះ មិនឲ្យកូនខ្លួន ដែលមិនទាន់បានធ្វើបន្តួលឧបនយននេះចូលទៅរួមបរិភោគអាហារជាមួយទេ បើកូននោះមិនទាន់បានប្រសិទ្ធិជាជាព្រាហ្មណ៍នៅឡើយទេ ។ ដូច្នេះ មាតាបិតាត្រូវនាំកូនប្រុស ឲ្យទៅរៀនគម្ពីរវេទខ្លះ ដើម្បីឲ្យកូនបាននាមថាជាទ្វិជៈ= ព្រាហ្មណ៍ ។ ពិធីនេះត្រូវធ្វើក្នុងពេលដែលកូនមានអាយុឋិតនៅចន្លោះឆ្នាំទី ៧ និងឆ្នាំទី ១០ បើទុកជាមិនហុចឲ្យទេ ត្រូវធ្វើដល់ទៅកូនអាយុបាន ១៦ ឆ្នាំក៏បាន ត្រូវ

ហៅញាតិមិត្រមកជួបជុំ ត្រូវមើលឫក្សពារឲ្យបានត្រឹមត្រូវល្អ មុនសិន មុនពិធី ត្រូវកោរសក់កូន ហើយប្រោះព្រំដោយគ្រឿងក្រអូប ។ ព្រាហ្មណ៍អ្នកធ្វើពិធី ត្រូវនាំកូននោះទៅគោរពទេវតាប្រចាំផ្ទះ ហើយឲ្យកូនក្រាបសំពះមាតាបិតានិងភ្ញៀវ រួចមកឲ្យកូនអង្គុយលើកៅអីឈើ ឪពុកអង្គុយទល់មុខ ហើយព្រាហ្មណ៍អ្នកធ្វើពិធីសូត្រគាថា រួចហើយកូនក្រាបសំពះឪពុកម្តងទៀត គោរពដោយស្ទាបជើងឪពុកដោយដៃ ឪពុកឲ្យពរកូននិងភ្ញៀវហើយ ប្រាចគ្រាប់ពូជស្វះទៅលើកូន ដើម្បីឲ្យកូនមានជោគ ។ ពេលនេះ ត្រូវដុតភ្លើងដោយឧសសក្តិសិទ្ធិ ដែលលាបដោយខ្លាញ់ទឹកដោះគោ ។ (ខ្សែចង) ត្រូវយកអម្បោះ ៣ សរសៃមកវេញជាមួយគ្នា ខ្សែ ៣ សរសៃនេះជាត្រីទេព ពណ៌ស ជាពណ៌បរិសុទ្ធ ។ ខ្សែនេះ ត្រូវព្រាហ្មណ៍ប្រសិទ្ធីមុននឹងយកទៅចងកូន កំពុងចងត្រូវសូត្រគាថាវេទ ចងខ្សែហើយកូនសូត្រគាថាតាមគ្រូ ។ ភ្ញៀវត្រូវ

ជាយចេញពីបន្ទប់ឲ្យអស់ ទើបព្រាហ្មណ៍ ប្ដូរគុកសូត្រគាថា
គាយត្រី ផ្ដុំបញ្ចូលខ្នងក្រោមទៀតកូនចាំងពីរោះផង ព្រោះពិធីនេះ
មិនត្រូវសូត្រនៅមុខកៀវទេ ៗ លុះសូត្រគាថាគាយត្រីនេះ
រួចហើយ កៀវចាំងឡាយចូលមកអង្គុយតាមកន្លែងដើមវិញ ៗ

ពីបុរាណ កាលធ្វើពិធីនេះរួចហើយ មាតាបិតាត្រូវយក
កូនទៅប្រគល់ឲ្យព្រាហ្មណ៍ជាគ្រូបង្រៀន ហេតុនេះបានជា
កើតពាក្យថា "ឧបនយន" នេះឡើង ៗ ឯពាក្យថា ឧបន-
យន នេះ ប្រែថា "កិរិយានាំកូនទៅប្រគល់ឲ្យគ្រូបង្រៀន"
ដូចជុំនៀមខ្មែរយើង នាំកូនទៅប្រគេនលោកឯវត្ត ៗ ឯខ្សែ
ចំណងនេះ ជាគ្រឿងសំគាល់ថាជាទ្វិជ:= ព្រាហ្មណ៍ ពេញ
លក្ខណ: មិនតែប៉ុណ្ណោះទេ ជានិមិត្តរូបនៃតំណតួជព្រមចាំង
ជឿថា មានអំណាចខាងសាសនាគឺនៃគន់ថែមទៀតផង ទើ
នមស្ការទេពតា ជនហិណ្ឌូត្រូវពាក់ខ្សែនេះឆៀងស្មា គឺលើ
ស្មាឆ្វេង ជាយខ្សែម្ខាងឲ្យនៅខាងក្រោមស្មាស្ដាំ បែបនេះហៅ

ថា " ឧបវីត " បើឧបស្ការបុគ្គលប្រុសត្រូវពាក់ខ្សែនេះលើស្មាស្តាំ ដោយទាញម្ខាងឲ្យនៅខាងក្រោមស្មាឆ្វេង ដែលនេះហៅថា "ប្រាចីនវីត" បើឧបស្ការព្រះអរហន្ត ត្រូវពាក់នៅកណ្ដឹ ដែលនេះហៅថា "និវីត" ។ ខ្សែសក្តិសិទ្ធិនេះ មិនត្រូវឲ្យទៅ[illegible]ពាក់ទេ បើដាច់ត្រូវប្រសិទ្ធិខ្សែពាក់មួយទៀត ។ ព្រាហ្មណ៍ខ្លះ ត្រូវផ្លាស់ខ្សែនេះមួយឆ្នាំម្ដង ។ រីឯខ្សែនេះ ផ្លូវការ[illegible]ដៃជើរ ក្នុងពេលធ្វើមង្គលការកូន សែនចងដៃ ក្នុងពេលបានជួបញាតិសន្តាន ដែលបែកគ្នាយូរ ហើយជាគ្រឿងសំគាល់ថាមានខ្សែស្រឡាយជាមួយគ្នា ។

១១- ពិធីមង្គលវិលមកផ្ទះវិញ ហៅថា "សមាវត៌ន" ។ ពិធីនេះ កាលដើមសំខាន់ណាស់ដែរ គឺកាលដែលកូនបានរៀនចេះចប់ហើយ ត្រូវត្រឡប់មកកាន់ផ្ទះវិញ ក្នុងពេលដែលកូនមកដល់ផ្ទះ មាតាបិតាញាតិសន្តានត្រូវមកជួបជុំគ្នា រង់ចាំទទួលដោយសេចក្តីត្រេកអរក្រៃលែង ព្រោះបាត់មុខកូនមក

អស់កាលយូរឆ្នាំហើយ ។ សព្វថ្ងៃនេះ ពិធីនេះមិនមានទេ ព្រោះគេត្រូវធ្វើបន្ទាប់ពីមង្គលឧបនយនវិញ ព្រាហ្មណ៍អ្នកធ្វើពិធីសូត្រគាថាវេទថា "ឥឡូវនេះ ឯងជាព្រហ្មចារី ឥឡូវនេះ ឯងជា គ្រហបតិ" តែប៉ុណ្ណោះ ក៏ចប់ពិធីឧបនយន និងសមាវត៌ននេះទៅ ។

១៤- ពិធីមង្គលការ ហៅថា "វិវាហ" ។ ពិធីនេះសំខាន់បំផុតជាងពិធីឯទៀតទាំងអស់ ត្រូវធ្វើក្នុងពេលដែលធី-តាចូលក្នុងតរុណវ័យ ដល់ធីតានេះមានរដូវហើយ មាតាបិតាត្រូវប្រាប់ដល់សង្គមទាំងមូលថា ធីតាខ្លួនល្មមរៀបចំការបានហើយ តែគេទុកស្ត្រីណាក្នុងពេលមានរដូវនេះថាជាស្ត្រីមិនបរិសុទ្ធ ។ ស្ត្រីព្រាហ្មណ៍ក្នុងពេលដែលខ្លួនមិនទាន់បានធ្វើឲ្យបរិសុទ្ធ មិនត្រូវឲ្យទៅលាយឡំក្នុងសង្គមបរិសុទ្ធទេ មិនត្រូវឲ្យចូលទៅក្នុងផ្ទះបាយចំអិនអាហារ ឬពាល់មនុស្សបរិសុទ្ធទេ ត្រូវឲ្យនៅតែម្នាក់ឯងដាច់ឡែក ស៊ីតែម្នាក់ឯង ។

ការធ្វើវិវាហមង្គលជាភារៈមាតាបិតា សាមីខ្លួនទាំងពីរមិនត្រូវ
ឲ្យជួបគ្នាទេ វៀរលែងតែជួបដោយមិនដឹងខ្លួន ព្រោះគេទុក
ថាជាការមិនបរិសុទ្ធ ។ សព្វថ្ងៃនេះ វិវាហៈ ជាពិធីដែលជន
ហិណ្ឌូនិយមខ្លះទៅ គេរៀបចំធ្វើតាមសាស្ត្រគម្ពីរវិស្សមាតាការ
នៃព្រាហ្មណ៍ ធំក្រៃលែងណាស់ មិនមែនតិចពីណាប្រសើរជាងទេ
មានក្បួនហែសម្បើមគ្រាប់ ។

តាមគម្ពីរមនុ, ស្ត្រីដែលល្អរៀបមង្គលការបាន គឺ
ស្ត្រីមិនពិការកាយ មានឈ្មោះក្រសេពគប់ មានដំណើរ
ណ្តាយល្អដូចដំរី កោមខ្លួនមុសត់ឲ្យមានចំនួនតិច ធ្មេញល្អិត
រឹមពតីរមាត់ល្អ ។ ស្ត្រីត្រូវមានសក់ក្រហមព្រៀងៗ មាន
អវយវៈ មិនសមរម្យ ឧ.ស្បែកហាក់ឈើច្រើន និយាយច្រើនឬភ្នែក
ក្រហម ពុំនោះឥតមានរោម ឬគឺមានរោមច្រើនពេក ទាំងអស់
នេះត្រូវវៀរចេញ ។ រដូវរៀបមង្គលការបាន គឺខែមាឃផល្គុណ
វិសាខ ត្រូវឲ្យហោរាគេទស្សន៍មើលឫក្សពេលាដូចខែរយ៉ើងថ្ងៃ ។

ពិធីមង្គលការផ្សេងៗគ្នាខ្លះតាមជនបទ ។ តែគោលសំខាន់នោះដូចគ្នាគឺ ត្រូវយកព្រះអគ្គិជាសាក្សី ព្រោះអគ្គិជាទេពតាសក្តិសិទ្ធិពិតរបស់ជនឥណ្ឌា ។ ត្រូវយកព្រះអគ្គិទៅដុតនៅកណ្តាលល្វែងដែលរៀបមង្គល ត្រូវយកខ្លាញ់ទឹកដោះដុតជានិច្ចតទៅកុំឲ្យរលត់ សព្វថ្ងៃនេះ គេយកបន្ទៀងប្រេងទៅដុតជំនួសវិញ កូនស្រីប្រុសត្រូវអង្គុយនៅក្បែរគ្នា ត្រូវតែកូនទាំងពីរនាក់ឲ្យបានល្អ កូនស្រីត្រូវយកសំពត់ប៉ុនៗ ហើយព្រាហ្មណ៍អ្នកធ្វើពិធីគោរពព្រះគណេស ជាទេពខាងឧបសគ្គ ដើម្បីការពារឲ្យមានមង្គល គេយកសំពត់មួយទៅចងនឹងជាយសំពត់កូនស្រីប្រុស-សូត្រគាថារួច ក៏កាន់សូត្រ ចាប់ដៃកូនស្រីប្រុសទាំងពីរទៅដាក់លើសំពត់ពិធីនេះ សូត្រគាថាវេទមន្តទៀត ព្រាហ្មណ៍ម្នាក់ទៀតជាអ្នកជួយ យកខ្សែទៅចងកណ្ដាកូនស្រីប្រុសទៀត ហើយបង្គាប់ឲ្យកូនស្រីប្រុសយកបាយ ជូន បោះទៅកន្លែងក្រានអគ្គិ ។ របៀបមង្គលការនេះវែងវែងណាស់ មាន

ការស្រោះទឹក បាចផ្កាក្រហម ដើរ ៧ ជំហាន ហៅថា "សប្តបទិ" គឺកូនស្រីប្រុសត្រូវដើរជុំវិញភ្លើងក្រានអគ្គិ ៧ ជុំ តាមបង្គាប់ព្រាហ្មណ៍ កូនប្រុសដើរមុខ កូនស្រីដើរតាមក្រោយ ៗ តាមគម្ពីរនិយាយថា "ជំហានទីមួយ ទុកជាអាហារ ជំហានទីពីរ ទុកជាកម្លាំង ជំហានទីបី ទុកជាសេចក្តីសុខ ជំហានទីបួន ទុកជាសេចក្តីចំរើន ជំហានទីប្រាំ ទុកជាកូនចៅ ជំហានទីប្រាំមួយ ទុកជារដូវ ជំហានទីប្រាំពីរ ទុកជាមិត្តសម្លាញ់" ឯកូនប្រុសក្រោយពេលទៅកាន់កូនស្រីថា "សូមសម្រេចផលខ្ញុំ សូមឲ្យមានកូនច្រើន សូមឲ្យមានអាយុវែងដល់ចាស់ជរា" ។

តាមគម្ពីរមនុ (III, 21) ការរៀបចំកូនប្រុសស្រីឲ្យជាប្តី-មីភរិយានេះ ហៅថា "វិវាហ" ន័យដើម "ការពង្រត់យក ឬការចាប់យកដោយកម្លាំង" ពោលដោយសង្ខេបមាន ៨ ប្រការ ៗ វិវាហ ៤ ប្រការខាងដើម សំដែងឲ្យឃើញថាជា

ចំនៀមបរមបុរាណនៃវណ្ណៈអ្នកបួស ជាពិធីការដែលប្រពន្ធស្លាប់ទៅហើយបានទៅកើតជានស្ងួត៌ ឯប្តីត្រូវបានទ្រព្យខាងស្រ្តីហៅថា ស្រ្តីធនៈ ជាមត៌កគឺ៖

១- ព្រហ្មវិវាហ ការរៀបការអោយកូនស្រីពេញចិត្តធ្វើជាភរិយា;

២- ទៃវវិវាហ ការរៀបការដោយស្លាប់ជាអ្នកបួសយជ្ញៈ ហៅថា ឫត្វិជ;

៣- អាស៌វិវាហ ការរៀបដោយបិតានៃកូនស្រី បានទទួលគោមួយនឹមដោយសន្មត;

៤ ប្រាជាបត្យវិវាហ ការរៀបការដោយការស្នើមកពីខាងកូនប្រុស;

៥- អាសុរវិវាហ សម្រាប់វណ្ណៈវៃស្យ និងសូទ្រៈ;

៦- គាន្ធវ៌វិវាហ ការរៀបការដោយមាតាបិតាទាំងសងខាងពេញចិត្ត;

៧- រាក្សសវិវាហ ការរៀបការដោយពួករាក្សសចាប់ព្រ័ត់ ដូចអ្នកចម្បាំងជាដើម បែបនេះ នឹងហៅថា រាក្សសវិវាហៈក៏បាន (ការរៀបការ ៣ ប្រការ គឺទី៥, ទី ៦, ទី ៧ នេះទុកជាការថោកទាប);

៨- បៃសាចវិវាហ ការរៀបការបែបបិសាច គឺចាប់ផ្ដាញ់ ដោយស្រវឹងស្រាជាដើម បែបទី ៨ នេះ ថោកទាបបំផុត ។

រៀបការប្តីប្រពន្ធ មានប្រពៃណីផ្សេង ៗ ច្រើនណាស់ ភរិយា អាចមានប្តីច្រើនក៏បាន របបនេះមានបុកណាទៅប្រទេស ឥណ្ឌា ហៅថា ពហុបតិភាព (Polyandrie) ដូចនាង ទ្រៅបតីក្នុងរឿងមហាភារត មានស្វាមីប្រាំនាក់គឺបងប្អូនបាណ្ឌព ទាំង ៥ ។ ការនេះ មិនទាស់នឹងច្បាប់សាសនាព្រាហ្មណ៍ ដែលហាមប្រាមមិនឲ្យយកញាតិសន្ដានសាច់ជិត ជាប្តីប្រពន្ធ ទេ ។ ឯប្តីក៏អាចមានប្រពន្ធច្រើនបានដែរហៅថា ពហុភរិយា ភាព (Polygamie) តែប្រទេសឥណ្ឌាជាប្រទេសក្រៅ ការ

យកប្រពន្ធច្រើនជាការធ្ងន់ណាស់ ប្ដីមានឋានៈក្រក្រមិនអាច
នឹងទ្រភារៈនេះបានទេ មានតែជនដែលមានឋានៈខ្ពង់ខ្ពស់ទេ
ទើបអាចមានទ្រព្យសម្រាប់ផាក់ស្រីណាភរិយាច្រើនបាន ៗ
ក្នុងយុគសម័យនេះស្ត្រីភាពមានសិទ្ធិស្រួលជ្រើសប្ដីបាន ហៅថា
ស្វយម្វរៈ តែសព្វថ្ងៃ ទំនៀមនេះមិនមាន ៗ ក្នុងសម័យដើមស្រុក
ខែរលោកគេតម អនុញ្ញាតឲ្យរៀបចំការជាមួយស្ត្រី ដែលមិន
ទាន់គ្រប់ការបាន គឺរៀបការតាំងតែពីកូនប្រុសស្រីនៅពីកុមារ-
ភាព ស្ត្រីកាយុ ១៣ ឬ ១៤ ឆ្នាំ ហើយឲ្យទៅនៅផ្ទះខាងប្ដី ហេតុ
ដូច្នេះឯង ហើយបានជា មានស្ត្រីមេម៉ាយច្រើនបិតនៅក្នុងវ័យ
ក្មេង ៗ ស្ត្រីមេម៉ាយដែលមិនមានកូន រៀបការម្ដងទៀត
បាន តែមតិមហាជនចូលចិត្តយកស្ត្រី ដែលតាំងចិត្តនៅជា
មេម៉ាយរហូតមកធ្វើជាប្រពន្ធ បើទុកជាប្ដីស្លាប់ពោល ៣ ឬ
៤ ឆ្នាំ ដោយកេតអុតឬកេតរបេងក៏ដោយ ៗ មួយទៀត
មតិមហាជន តែងដឹកនាំឲ្យស្ត្រីលោតទៅក្នុងភ្លើងជួរស្លាប់ជា

មួយប្ដី ៗ ក្នុងគម្ពីរ អថវវេទ (18, 3, 1) មានគ្រា-
ទុកនូវទំនៀមចូលស្លាប់ជាមួយប្ដីនេះ ។ តែតាមមតិរបស់យើង
គ្រប់គ្នាឃើញថា ទំនៀមនេះមិនប្រពៃសោះសម្រាប់មនុស្ស
ខ្លះទៅ ព្រោះជំនឿថាលោកស្លាប់ទៅជាមួយប្ដី ហើយបានទៅ
កើតក្នុងឋានសួគ៌ មិនមែនជាសច្ចធម៌ទេ ។ មួយវិញទៀត
ស្ត្រីដែលប្ដីស្លាប់ចោលទៅហើយ មិនមានករណីយកិច្ចនឹង
ត្រូវធ្វើតាមលទ្ធិសាសនាឡើយ បើថាស្លាប់ត្រូវស្លាប់ទៅជា
មួយប្ដី ទើបបានទៅកើតក្នុងឋានសួគ៌ ។ គម្ពីរមនុនិយាយ
ថា "ន ស្ត្រី ស្វាតន្ត្រ្យម៑ ប្រែថាស្ត្រីទាំងអស់ មិនបាន
សិទ្ធិតាមទំនើងខ្លួនឯងទេ" ។ តាមច្បាប់ ប្រុសមិនត្រូវ
យកភរិយាដែលជាញាតិសោះ, ខ្មែរយើងក៏កាន់តាមទំនៀម
នេះដែរ បើទុកជាត្រូវរៀបការជាមួយវណ្ណៈខ្លួន ក៏ត្រូវហាម
ឃាត់មិនឲ្យរៀបការជាមួយស្ត្រីសបិណ្ឌ គឺស្ត្រីដែលមានបុរ
ប្អូនប្រុសគោត្រពុកបុរសដូចប្ដីក្នុងអនាគត ។ តាមគម្ពីរ

គោតម (IV, 1) ប្រុសមិនត្រូវរៀបការជាមួយស្រីគោត្រជាមួយគ្នាទេ=សគោត្រ សមានប្រវរ ព្រោះទុកដូចជាសបិណ្ឌក្នុងគ្រួសារដែរ ។

X X X

ហិណ្ឌូធម៌ (ច្បាប់) .– ប្រពៃណីហិណ្ឌូត្រូវប្រតិបត្តិតាមច្បាប់ ដែលមានក្រោទុកក្នុងគម្ពីរ ច្បាប់នេះហៅថា "ធម៌" ជាច្បាប់ដែលអ្នកប្រាជ្ញបានចងក្រងទុក សម្រាប់ឲ្យប្រជាជនកាន់តាមនៅក្នុងគ្រួសារនីមួយៗ ដូចជាច្បាប់ក្នុងគម្ពីរព្រាហ្មណៈ ដែលកើតមានយូរមកហើយ ប្រហែលជារវាងសតវត្សទី ៨ មកដល់ទី ៣ មុនគ្រិស្តសករាជ ច្បាប់នេះមិនមែនជារឿងដែលហៅថា "ស្រុតិ នោះទេ គឺជាប្រពៃណីដែលហៅថា ស្មតិ" ។

ច្បាប់ប្រពៃណីនេះ ហៅថា ធម៌សាស្ត្រ ជាគម្ពីរមួយ

និយាយពីប្រពៃណីនិងពិធីដែលជាករណីយកិច្ចត្រូវប្រតិបត្តិ ៗ អត្ថបទនីមួយ ៗ នេះ ជាសូត្រ ហើយមានដាក់គាថានៅចន្លោះ ៗ ប្រាប់ឈ្មោះលទ្ធិ ឬ ប្រពៃណីគ្រួសារព្រមទាំងពិធីផង ៗ គម្ពីរដែលចាស់ជាងគេ គឺគម្ពីរធម៌សាស្ត្រៈរបស់អ្នកព្រាហ្មណ៍គោតម អ្នកព្រាហ្មណ៍ពៅធាយនៈ និង វាសិដ្ឋ ដកស្រង់ចេញមកពីគម្ពីរសាមវេទ គឺគេប្រមូលយកមកចម្រុះគ្នាទុកជាច្បាប់ ៗ ធម៌សូត្ររបស់អ្នកព្រាហ្មណ៍ វាសិដ្ឋ ជារបស់លទ្ធិហិណ្ឌូភាគខាងជើង យកតាមគម្ពីរធម៌សូត្ររបស់មនុ រីឯជាដើមកំណើតគម្ពីរ មានធម៌សាស្ត្រក្នុងបុព្វកាល សូត្ររបស់អ្នកព្រាហ្មណ៍អាបស្តម្ភៈ ចេញមកពីគម្ពីរយជុរ្វេទខ្មៅ ជាលទ្ធិហិណ្ឌូភាគខាងត្បូង ប្រហែលជាកើតមានឡើង ៤០០ ឆ្នាំ មុនគ្រិស្ត-សករាជ ជាកាលបរិច្ឆេទមុនសូត្រៈរបស់អ្នកព្រាហ្មណ៍ពៅធាយនៈបន្តិច ៗ គម្ពីរទាំងពីរនេះ ជាគម្ពីរចាស់ជាងគេបំផុត គេដកស្រង់ចេញពីសូត្រៈ របស់លោកហារិតៈក្នុងវេទជាមួយគ្នា

តែជាលទ្ធិ មៃត្រាយនីយៈ ។

មួយទៀត គម្ពីរជាន់ក្រោយ មិនមុនគ្រិស្តសករាជ ២០០ ឆ្នាំទេ ដូចគម្ពីរធម៌សាស្ត្រនៃលទ្ធិវិស្ណុៈ ហៅថា វិស្ណុស្ម្រឹតិ ដកស្រង់ចេញពីសូត្រៈចាស់នៃលទ្ធិកាឋកៈ ក្នុងគម្ពីរយជុរវេទ ទៅ ។ ឯស្ម្រិតិដទៃទៀត ដូចមនុស្ម្រិតិ ឬមួយទៀតហៅថា មានវធម៌សាស្ត្រជាដើម គម្ពីរនេះ អ្នកអឺរ៉ុបយកមកប្រែហើយ ហៅថា (Loi de Manu) ។ គម្ពីរទាំងនេះ កើតក្នុងសម័យគម្ពីរមហាភារតៈ ព្រោះមានជាប់លទ្ធិសាសនាប្រជា-ជនទូទៅ ដែលគេយកមកពីគម្ពីរមហាភារតៈ មានទាំងស្នាដៃសម្រាប់ខាងការបង្រៀន ខាងកវីនិពន្ធ ខាងទស្សនវិជ្ជាផង ផ្ទុយគ្នានឹងគម្ពីរជាន់ចាស់ ដែលក្រៀមក្រោះមិនមានរសជាតិអ្វី ។ ឯស្ម្រិតិរបស់លោកយាជ្ញវល្ក្យ កើតក្នុងសម័យជាមួយគ្នាដែរ តែជារបស់គ្ឫហ្យសូត្រក្នុងគម្ពីរយជុរវេទស ជារបស់លទ្ធិហិរណ្យ

ភាគខាងកើត មានពាក្យពេចន៍ច្បាស់លាស់ហ្មត់ចត់ ហើយ
ប្រសើរជាងគម្ពីរមនុះទាំងទៀត ហើយមានចំនួនច្បាប់សាស្ត្ររបស់
លោកនានា ៗ ឯសាស្ត្ររបស់លោកព្រហ្មទត្ត បើលឲ្យល្អិត
ទៅ ឃើញថាកើតមុនសាស្ត្រនានា ប៉ុន្តែបែបជាគជ្ជូតជារបស់
មនុស្ស ហើយកើតមុនសាស្ត្ររបស់លោកបេតាក់ចិ ដែលជា
អ្នកគតិច្បាប់មុនដំបូង ជាបែបបុរាណ (Classique) គឺ
ត្រឹមត្រូវតាមក្បួន ៗ គម្ពីរផ្សេង ៗ ជាដើម សុទ្ធតែមាន
និយាយពីប្រពៃណី ដែលគេប្រើគ្នាសម័យគម្ពីរចប់តា ស្រុកពី
បុរាណ និងតាចាស់ ៗ ពីបុរាណទៀតផង ហើយទុកជា
បែបការសិក្សាខាងប្រពៃណីនិយម (Folklore) ពាសពេញ
ទ្វីបអាស៊ី ៗ

និយាយដោយឡែក សង្គមឥណ្ឌា ជាសង្គមចាក់ចង

ដោយលទ្ធិសាសនា ៗ ទស្សនវិជ្ជាទេពនិយម (Philosophie Panthéistique) នៃជនហិណ្ឌូ បដិសេធមិនឲ្យមានសេចក្តីយល់ឃើញជាឯកតាធិបតេយ្យទេ (Individualisme) តែបើនិយាយតាមការគាំទ្រចិត្តប្រតិបត្តិវិញ ជនហិណ្ឌូជាឯកតាធិបតេយ្យ ៗ រចនាសម្ពន្ធ (Structure) នៃសង្គមហិណ្ឌូ មានការចែកវណ្ណៈជាពួក ហើយមានចិត្តផ្ទង់លំអៀងទៅខាងការប្រកាន់វណ្ណៈនេះណាស់ ៗ របៀបការចែកវណ្ណៈនេះជាការនាំឲ្យបែកសង្គម មិនមែនជាការនាំឲ្យមានសាមគ្គីជាឯកភាពទេ ៗ វណ្ណៈមួយៗ មានអនុវណ្ណៈតទៅទៀត ហើយហាមមិនឲ្យស៊ីជាមួយគ្នា មិនឲ្យរៀបការជាមួយគ្នា មិនតែប៉ុណ្ណោះទេ ការទាក់ទងគ្នា ក៏ត្រូវមានការកំរិត សព្វបើស៊ីបាយជាមួយវណ្ណៈជាមួយគំរោយ ហើយមានពិធីសម្រាប់លាងចានទៀត ៗ កំរិតការទាក់ទងទៅលើសង្គមបែបនេះនាំឲ្យជនហិណ្ឌូមានគំនិត ដើរចេញពីសង្គមទៅស្វះស្វែងរកទី

ឋានស្ងប់ស្ងាត់ ដែលនាំផែនដីតលវិសាសនាក្នុងការសំគា

សង្ស័យ តែសមាគមមិនអាចនឹងបិតបាំងវាទៅបានទេ. ប្រសិន

បើមិនមានការជាប់គ្នាខាងសង្គមកិច្ច ៗ ជនហិណ្ឌូទាំងអស់ត្រូវ

កាន់ច្បាប់នេះដោយដាច់ខាត មិនមានការវៀរលែងឡើយ ៗ

ជនហិណ្ឌូដែលជាអនុវណ្ណៈ នៅជនបទក្តី នៅក្រុងក្តី

តែងមានគណៈបញ្ចាយ័ត (Pancayat) មួយ សម្រាប់វណ្ណៈ

របស់ខ្លួន ៗ បញ្ចាយ័តនេះ ជាស្ថាប័នហិណ្ឌូពីបុរាណជាក្រុម

ជនអ្នកកាន់អំណាចសម្រាប់សម្រេចសេចក្តី ពីការទាស់ទែ

គ្នាតាមផ្លូវច្បាប់ ៗ ពាក្យថា បញ្ចាយ័តបានសេចក្តីថា “ស

មានជន ៥ នាក់” តែចំនួននេះ មិនមែនជាការកំរិតទេ

ឯសមាជិកបញ្ចាយ័តនេះទៀតសោត ក៏មិនមានការៈជួន ឬ

ដេរទៅដែរ ក្នុងជនបទខ្លះ អ្នកកាន់អំណាចតែងតាំងឡើង

ជនបទខ្លះទៀត អ្នកស្រុកជ្រើសតាំងឡើង ឯជនបទដទៃទៀត

កាន់តៗ គ្នាពីជីដូនជីតាមកក៏មានដែរ គណៈជនបញ្ចាយ័តនេះ

មានទំនងដូចមេបាវ៉ែតាមគម្ពីរពីបុរាណ មានសិទ្ធិត្រូវវិន័យទោស ឬដាក់ទោស ឬកំដេញពីវណ្ណៈខ្លួន ។ ការបណ្ដេញពីវណ្ណៈនេះ ជាការយោរយៅណាស់ ។ ឯសកម្មភាពកងការកំណត់វេក្កនៃអនុវណ្ណ របស់ខ្លួននេះ ជាការសំខាន់ខាងសង្គមនិងខាងសាសនា ផងព្រាហ្មណ៍ដែលត្រូវគេបណ្ដេញចេញពីវណ្ណៈហើយមិនត្រូវមានគ្នាស្រីប្រុសរៀបចំការទេ មិនត្រូវទទួលធាតុទានបទាតមិន [illegible] ក្រាបកុលសម្ព័ន្ធ) ។ នំពិណ្ឌវណ្ណៈខ្ពស់ ដែលត្រូវគេបណ្ដេញហើយ វណ្ណៈទាបក៏មិនត្រូវព្រមទទួលឱ្យនៅជាមួយខ្លួនដែរ ព្រោះគេប្រកាន់ជឿថាជា "យូតា=ការបាក់ទាប" ចង្រៃធំណាស់ វណ្ណៈដទៃទាំងអស់ ត្រូវហាមដាច់ខាតមិនឱ្យទទួលគ្រួសារអ្នកដែលគេត្រូវបណ្ដេញនោះទេ គ្រាន់តែគេពាល់កែវកុដិករបស់ខ្លួនក៏មិនបានដែរ ។

ការបណ្ដេញពីវណ្ណៈនេះ មានការខ្វះក៏ត្រូវបណ្ដេញ ការ

ខ្លះទៀតក៏មិនត្រូវបណ្ដេញដែរ ការត្រូវបណ្ដេញនោះគឺសម្រាប់គេ ស៊ីសាច់គោ ឬស៊ីបាយជាមួយវណ្ណៈទាប ធ្វើដំណើរឆ្លងសមុទ្រ បើមិនដឹងហើយទៅស៊ីបាយរបស់ជនវណ្ណៈទាបដួលដាំឲ្យ ត្រូវបណ្ដេញអ្នកនោះ ។ សង្គមហិណ្ឌូ ជាសង្គមតាមលទ្ធិសាសនា មានគណៈបញ្ញវ័តជាអ្នកនាំមើលការខុសត្រូវក្នុងវណ្ណៈខ្លួន ជាប្រពៃណីបរមបុរាណយូរយារណាស់ហើយ គេរក្សាទុករហូតមកដល់សព្វថ្ងៃនេះ, តែជនហិណ្ឌូសម័យថ្មីមិនកាន់តាមប៉ុន្មានទេ ។

វណ្ណៈ.- សង្គមហិណ្ឌូ មានការបែងចែកមនុស្សជាតិជាជាន់ថ្នាក់ខ្ពស់ទាប ។ ការបែងចែកបែបនេះ គេឲ្យឈ្មោះថា វណ៌ (ប.វណ្ណ) ប្រែថា "ពណ៌" ហើយអ្នកអស្ដង្គ-ប្រទេសហៅថា កស្ត (Caste) ។ "កស្ត" នេះ ជាពាក្យពរទុគេស ប្រែថា "ជាតិ,កំណើត" មិនមានន័យសមរម្យទៅតាមវណ្ណៈហិណ្ឌូទេ ។ រឿងការបែងចែកវណ្ណៈនេះ កើត

មានៈឡើងក្នុងសម័យនេះ ជារឿងសំខាន់ណាស់ ក្នុងសម័យនោះ ៗ ឯបុព្វហេតុដើម ដែលនាំបង្កបង្កើតឲ្យមានវណ្ណៈខ្ពស់ទាបជួរចុះឡើង គឺកើតមកពីការរុករានពីខាងក្រៅ នៃពួកជនដែលមានអានុភាពៈច្រើនជាង ចូលមកក្នុងដែនដីណា ហើយតាំងទីលំនៅរបស់ខ្លួន ៗ កាលជនពួកនេះ មកតាំងទីលំនៅមាំមួនហើយ ក៏កើតជាប្រស្នាវណ្ណៈនេះឡើង ដើម្បីប្រកាន់កុំឲ្យលាយឡំជាតិខ្លួន ហើយលើកដំកើងឈ្មោះពួកខ្លួនថាអារ្យ័ន ប្រែថា "ប្រសើរ ឬមានសេរីភាព" ឯផ្ទ-រាសីអ្នកដើមកំណើតស្រុក ជាកុលសម្ពន្ធ ទ្រាវីឌ, មីលក្ខ "អ្នកព្រៃ ឬ អ្នកភ្នំ", ទាស, ទស្យុ ( ដែលគេទុកជាឈ្លើយ ឬជាអរិៈសត្រូវ) ក៏មកមានន័យប្រែទៅជា "ខ្ញុំកំដរ" ទៅវិញ ៗ បុព្វហេតុមួយទៀត អ្នកប្រាជ្ញខ្លះយល់ថារឿងពណ៌សម្បុរស្បែក ព្រោះពួកអារ្យ័នជាជាតិពណ៌ស្បែកស ឯពួកដើមស្រុក មានកុលសម្ពន្ធ ទ្រាវីឌជាដើមនោះ ជា

ជាតិស្បែកពណ៌ខ្មៅ ។ លុះពួកស្បែកពណ៌សចូលមកនៅបានធ្វើជាចៅហ្វាយនាយហើយ ក៏កើតមានការមើលងាយពួកដើមស្រុក ដែលមានស្បែកពណ៌ខ្មៅ ហើយដែលធ្លាក់ខ្លួនមកជាទាសៈរបស់ខ្លួនទៀត នេះហើយជាហេតុដើមដែលនាំឲ្យបែងចែកមនុស្សជាតិជាជាន់ថ្នាក់ ដោយប្រកាន់យកពណ៌សម្បុរស្បែកនេះមកជាបន្ទាត់ ។ តមកក្ដីកាលជាជាតិក្រោយ ទៀតការបែងចែកវណ្ណៈ [illegible] ហៅជាច្បាប់ប្រពៃណីសង្គមទៀតហៅថា "វណ្ណធម៌" ។

ពេលសម្ពន្ធនៃសង្គមវណ្ណ [illegible] ក្រមធម៌ ប្រែថា "ច្បាប់របស់វណ្ណៈ ៤ និងក្រម គឺតំណែងក្នុងក្រមទាំង ៤ នៃជីវិតព្រាហ្មណ៍" ។ កាលដើមឡើយ ក្នុងសម័យវេទពួកអារ្យ៉ែន បែកវណ្ណៈត្រឹមតែ ៣ ទេ គឺ ព្រាហ្មណៈ ក្សត្រិយៈ និង វៃឝ្យ ដូចនៅប្រទេសអ៊ីរ៉ង់ (Iran) ដែលមានតែ ៣ ដែរ គឺ អថ្រវ៉ាន់ (Athrevans) ពួកអ្នកបួស, រថេស្តារ

(Rathaesthes) ពួកអ្នកចម្បាំង និង វាស្ត្រិយស-ភូយទ្យ (Vastriyas Fshouyants ឬ Huitis) ជាប្រជាជនទូទៅ (La masse populaire) ។ ទីបំផុត រឿងនេះក៏កើតទៅជា វណ្ណៈ ៤ គឺ ព្រាហ្មណៈ ១ ក្សត្រិយៈ ១ វៃស្យៈ ១ ឝូទ្រៈ ១ ។ ការបែងចែកជាវណ្ណៈ ៤ យ៉ាងត្រឹមប៉ុណ្ណោះ នៅមិនទាន់គ្រប់គ្រាន់ទេ គេមានច្បាប់បញ្ញត្តិឲ្យមានគ្រឿងស្លៀកពាក់ មានពណ៌សម្គាល់ គ្នា ទៀត គឺ ព្រាហ្មណ៍ស្លៀកពាក់ ពណ៌ស ក្សត្រិយ៍ស្លៀកពាក់ពណ៌ក្រហម វៃស្យៈស្លៀកពាក់ពណ៌លឿង ឝូទ្រៈ ស្លៀកពាក់ពណ៌ខ្មៅ ពួកវណ្ណៈខ្ពស់និងពួកវណ្ណៈទាប សមាគមជាមួយគ្នាមិនបានទេ ដេកបន្ទប់ជាមួយគ្នា ឬបរិភោគអាហារជាមួយគ្នាក៏មិនបាន ហាមប្រាមមិនឲ្យជណ្ដឹងយកវណ្ណៈខ្ពស់គ្នាជាស្វាមីភរិយា ដោយដាច់ខាត បើណាតែកន្ទ ទៀតគឺ វណ្ណៈខ្ពស់ទៅយកវណ្ណៈទាបជាស្វាមីភរិយា ហើយ មានកូនកើតមក កូននោះ ត្រូវមានគ្រោះកាចចោលផែនក្រក់

ណាស់ ជាមតិត ព្រោះកើតមកត្រូវគេហៅថាកូន "ចណ្ឌាល" ថោកទាបបំផុតជាងសត្វតិរច្ឆានទៅទៀត ។

បើនិយាយពីវណ្ណៈនេះ ទោះប្រឹងប្រែការណាស់ ក៏ពិបាកយល់មិនអស់ឡើយទេ បើមានការផ្លាស់ប្តូរលក្ខណៈ ពាក្យថា វណ្ណៈនេះ ក៏ត្រូវមានន័យផ្សេងពីទៀត តែបើគិត ក៏មិនមានផ្លាស់ប្តូរ ព្រោះនៅតែមានវណ្ណៈដដែលនេះនៅតែជាប់ បើទុកជាសាសនាព្រាហ្មណ៍ ផ្លាស់ប្តូរទៅជាដ៏ ណាក៏ដោយ វណ្ណៈក៏នៅតែជាវណ្ណៈដដែល ផ្លាស់ប្តូរទៅណាមិនបាន ។ ។ សម័យពុទ្ធកាល យើងបានដឹងថា ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់បានព្យាយាមធំបំផុត ទ្រង់បានសំដែងពីវណ្ណៈនេះដោយល្អិត ដើម្បីបដិវត្តសង្គមហិណ្ឌូឲ្យបានប្រសើរ តែការនេះមិនបានសម្រេចផលល្អទេ ។ សេចក្តីនេះ មានមនុស្សខ្លះទៅនិយាយថា ពុទ្ធសាសនាជាសាសនាចំលាយបង្រួមវណ្ណៈ ថានេះមើលទៅសមដែរ តែបើពិត ព្រះសម្ពុទ្ធទ្រង់គ្រាន់តែកែញែកឲ្យ

ឃើញទោសវណ្ណៈជាក់ស្តែងប៉ុណ្ណោះទេ ទ្រង់មិនមានព្រះកជ-
ហឫទ័យប្រកបដោយអគតិឡើយ ។ បើគ្រាន់តែទ្រង់សំដែង
ប្រាប់ខុសត្រូវ ដោយព្រហ្មវិហារធម៌ តើយើងយល់ថាទ្រង់
បំផ្លាញរបស់គេចោលដែរឬអ្វី ?

ក) វណ្ណៈព្រាហ្មណ៍.– ព្រាហ្មណ៍ជាធំខាងផ្នែកសាស-
នា ហើយមិនព្រមទុកដាក់វណ្ណៈខ្លួនថាទាបជាងក្សត្រិយ៍ទេ
ទុកវណ្ណៈខ្លួនជាវណ្ណៈនៃសង្គមទីមួយ ព្រាហ្មណ៍ស្ត្រីក៏បាននាម
ថាជាព្រាហ្មណី កូនកើតមកក៏បាននាមថា ជាព្រាហ្មណ៍ទៀត
គ្រាន់តែមិនទាន់ពេញលក្ខណៈសម្បូណ៌ប៉ុណ្ណោះ លុះត្រាតែ
មានកិច្ចធ្វើពិធីបន្តក់ប្រសិទ្ធិឲ្យទៅជាព្រាហ្មណ៍ទៀត ទើបបាន
ជាព្រាហ្មណ៍ពេញលក្ខណៈ ហេតុនេះហើយបានជាព្រាហ្មណ៍
មានឈ្មោះមួយទៀតថា ទ្វិជៈ ប្រែថា "មានកំណើតកើតពីរដង"
ដូចជាសត្វមានស៊ុតកើតពីរដង គឺកើតជាស៊ុតម្ដង កើតចេញពី
ស៊ុតមកម្ដងទៀត ។

មួយទៀត រឿងព្រេងតំណាលទុកថា ព្រាហ្មណ៍នេះ
កើតមានឡើងដោយពួកតាបសឬសី ឬមុនិ មុនប្រវត្តិសាស្ត្រ
ដែលបង្កើតពាក្យថា "ព្រហ្ម" នេះឡើង ហើយយកឈ្មោះ
ខ្លួនថា "ព្រាហ្មណ៍" ជាបន្ទោន ពាក្យថា ព្រហ្មិ នេះ បើតាម
ន័យខាងនិរុត្តិសាស្ត្រ គឺជា ទេវតានៅជាមនុស្សលោកយើង
នេះ ហើយជាគ្រូនៃសត្វមនុស្សលោកផង ។ តាមគម្ពីរមនុ
មានសេចក្ដីថា ព្រាហ្មណ៍នេះ កើតចេញមកពីមាត់ព្រះព្រហ្ម
(ឬថាជាមាត់ព្រះព្រហ្ម) ជាអ្នកធ្វើពិធីយញ្ញៈ ។ កំណើត
ព្រាហ្មណ៍ ឬ ព្រហ្មិន គឺជាអវតារនៃធម៌ៈ ជាអាទិទេពក្នុង
សាសនាព្រាហ្មណ៍ ។ មាត់ព្រាហ្មណ៍ជាមាត់អាទិទេព រីមួយ
ដែលគេយកទៅដាក់ក្នុងមាត់ព្រាហ្មណ៍ គាបនាំឲ្យកើតសេចក្ដី
ចំរើនដល់ពិភពលោកបាន សមដូចពាក្យថា៖

ពិភពលោកទាំងមូលនៅក្រោមអំណាចអាទិទេព
– អាទិទេពនៅក្រោមអំណាចមន្ត្រៈ

- បទ្រៈ នៅក្រោមអំណាចព្រាហ្ម... ព្រហ្មន

- ដូច្នេះ ព្រាហ្មណ៍ជាអាទិទេពរបស់យើង ។

កាយព្រាហ្មណ៍ជាវត្ថុសក្តិសិទ្ធិ ការសម្លាប់ព្រាហ្មណ៍ មានទោសធ្ងន់ណាស់ ទុកដូចសម្លាប់ទេវតា ការបៀតបៀន កាយព្រាហ្មណ៍ មានទោសធ្ងន់បន្ទាប់មកទៀត ។ ក្សត្រិយ៍ មិនមានច្បាប់នឹងប្រទុស្តដល់រូបកាយព្រាហ្មណ៍ទេ បើឝូទ្រៈ សម្លាប់ព្រាហ្មណ៍ អ្នកប្រព្រឹត្តបាបឃាតកម្មនេះ ត្រូវមានទោស ដល់ស្លាប់ ។ ជីវភាពព្រាហ្មណ៍ចែកទៅជាអាស្រមឬដំណាក់ (Stages) មាន ៤ ប្រការគឺ ព្រហ្មចរ្យ ១ គ្រហស្ថ ១ វនប្រស្ថ ១ សន្យាសិន ១ ។

១– កាលនៅវ័យក្មេង កុមារព្រាហ្មណ៍ជាអន្តេវាសិក ត្រូវសិក្សាត្រៃវេទ មានឈ្មោះថា ព្រហ្មចារិន កុមារនេះ ត្រូវប្រព្រឹត្តព្រហ្មចរ្យ ហើយមានភារៈគេងស សម្រាប់ដុតបំពក់ បង្ក្រានអគ្គិ ដើរសូមទានអាហារពីពួកញាតិសន្តាន ដកឈើ

...សន្និបាត ប្រតិបត្តិតាមទំនៀមសាសនាព្រាហ្មណ៍ ត្រូវមានគ្រូជា ជៀនរៀនផលស្គាល់ផ្លូវ និងមានកុក្រមាគឺជាអ្នកប្រាជ្ញា ស្តាប់គ្រូ ហើយត្រូវបង្គាប់ត្រឡប់មកកាន់ផ្ទះបិតាខ្លួនវិញ ការប្រព្រឹត្តនេះ ហៅថា ព្រហ្មចារ្យ អ្នកប្រព្រឹត្ត ហៅថា ព្រហ្មចារិន ។ល។

២– កាលសិក្សាត្រៃវេទចប់ហើយ ត្រឡប់មកផ្ទះវិញ កុមារត្រូវរៀបចំធ្វើអាពាហមង្គលគឺមានភរិយា ដើម្បីឲ្យទៅជា ម្ចាស់ផ្ទះ ហៅថា គ្រហបតិ ត្រូវប្រព្រឹត្តធម៌ ៣ ប្រការគឺ អថ៌-កាម ធម៌(១) ហើយមានភារៈត្រូវបំពេញកិច្ចការគោរពគឺធ្វើ គ្រឿងសែនចំពោះទៅបុព្វបុរស ដែលចែកឋានទៅហើយ ការប្រព្រឹត្តនេះ ហៅថា គ្រហស្ថ ។ល។

---

១– ហៅថា ត្រីវគ៌ ឬ ត្រីគណៈ សភាព ៣ ប្រការនេះគឺ អថ៌ៈ ធ្វើឲ្យចំរើន = វឌ្ឍនធម៌ (Progrès), កាមៈ បរិភោគកាម = សភាពតាំងនៅ (Etat stationnaire), ធម៌ៈ រកធម៌ = ការរលត់ទៅ (Déclin)

៣– លុះបានបំពេញកិច្ចជាគ្ឫហបតិបរិបូណ៌ហើយ ព្រាហ្ម-ណ៍នេះ ត្រូវប្រគល់ គ្ឫហបត្យភាពជាគហបតិ (Succession) ទៅឲ្យកូនហើយចេញទៅនៅព្រៃ សឹងស្នាធ៍អប់រំបន្ទុំអាត្មាឲ្យបានប្រពៃឡើង ហៅថា វនប្រស្ថ ។ល។

៤– លុះបានសឹងស្នាធ៍អប់រំបន្ទុំអាត្មាប្រពៃហើយ ព្រាហ្មណ៍នេះ បានអាស្រម ឬតំណែងទី ៤ ហៅថា សន្យាសិន អ្នកប្រព្រឹត្ត ហៅថា សន្យាសិន ប្រែថា អ្នកប្រព្រឹត្តធម៌លះលោកនេះទៅធ្វើជាតាបសឬជាភិក្ខុ ។

១) វណ្ណៈក្សត្រិយ៍.– ក្សត្រិយ៍ (ប.ខត្តិយ) ប្រែថា អ្នកច្បាំង មាននាទីជាអ្នកពង្រីកខេត្តដែន ព្រមទាំងរក្សាខេត្តដែនទុកឲ្យគង់ដោយប្រពៃ ប្រកាន់ជឿថាខ្លួនជាខ្សែស្រឡាយតមកពីព្រះអាទិត្យដែលហៅថា សរិយ ។ ឯព្រះនាមព្រះសម្ពុទ្ធថា គោតម នោះ ក៏បានសេចក្តីថា "ព្រះអាទិត្យ" ដែរ ។

មួយទៀត ក្សត្រិយ៍នេះ ក្នុងគម្ពីរព្រាហ្មណ៍ កើតចេញមកពីដៃព្រះព្រហ្ម (ឬជាដៃព្រះព្រហ្ម) មានភារៈជាអ្នករក្សាសង្គម មិនឲ្យមានការវៀកវៀនមកពីខាងក្រៅ ។ តាមច្បាប់ ក្សត្រិយ៍ ត្រូវធ្វើជាស្តេចនិងទាហាន (អ្នកចម្បាំង) ឬជាខ្លួនសម្រាប់ការពាររក្សាព្រាហ្មណ៍និងគោ ហើយត្រូវយកព្រាហ្មណ៍ដែលមានភ័ក្ត ឈ្មោះ មានការចេះដឹងនៃត្រៃវេទនិងធម៌-សាស្ត្រ ទាញមកធ្វើជាបុរោហិត ។ល។

គ) វណ្ណៈវៃស្យ.- វៃស្យ (ប.វេស្ស) បានដល់អ្នកជំនួញ តែមិនមែនស៊ីសេចក្តីត្រឹមតែអ្នកជំនួញទេ អ្នកជំនួញសម័យនោះ មិនមែនដូចអ្នកជំនួញសម័យយើងនេះទេ ព្រោះអ្នកធ្វើស្រែចំការ ក៏ចាត់ទុកនៅក្នុងពួកវៃស្យ អ្នកកស៊ីចិញ្ចឹមជីវិតដទៃទៀត ក៏គេទុកថាជាវៃស្យ លើកលែងតែទាសកម្មករប៉ុណ្ណោះចេញ ។

មួយទៀតវៃស្យ តាមគម្ពីរព្រាហ្មណ៍គេថា កើតចេញមក ពីភ្លៅព្រះព្រហ្ម (ឬជាភ្លៅព្រះព្រហ្ម) មានការងារជាអ្នកធ្វើផលិត-ផលឲ្យកើតបរិបូណ៌ឡើងដល់ប្រទេសជាតិ ហើយត្រូវដាក់ពន្ធដល់ព្រាហ្មណ៍និងក្សត្រិយ៍ ព្រមទាំងកសាងសេនាសនៈ មានវិហារជាដើម ឬជាដល់ព្រាហ្មណ៍ទៀតផង ៗ វៃស្យនេះជាព្រាហ្មណ៍ដែរ ព្រោះជាជាតិកាយពីពូជគ្នា តែមានឋានៈទាបបន្ទប ៗ

ឃ) វណ្ណៈសូទ្រ: .- សូទ្រ: (ប.សុទ្ទ) បានដល់ពួកអ្នកក្រ ឬ អ្នកស៊ីឈ្នួល ដូចពួកកម្មករយើងក្នុងបច្ចុប្បន្នកាលនេះ ៗ វណ្ណៈនេះថោកទាបជាងគេបំផុត ៗ

មួយទៀត សូទ្រ: ក្នុងគម្ពីរព្រាហ្មណ៍គេថា កើតចេញមកពីបាទជើងព្រះព្រហ្ម (ឬជាជើងព្រះព្រហ្ម) បានជាគេទុកដាក់ថាថោកទាបជាងគេ ៗ មានវណ្ណៈថោកទាបជាងសូទ្រ: ទៅទៀតហៅថា អនុវណ្ណ: ឬ ហីនជាតិ ដូចពួកចណ្ឌាល

ជាដើម រូបពួកវណ្ណៈជាតទាបទាំងអស់នេះ ហៅថាបញ្ចមៈ អ្នកអស្ពឹស្ស ហៅថា F.Hors castes Intouchables, A.outcastes ហើយមានឈ្មោះសម្រាប់ហៅផ្សេង ៗ គ្នាតាមដនបទ ៗ ក្នុងគម្ពីរមនុ មានសេចក្ដីថា បើកូនកើតពីនាងព្រាហ្មណ៍ដែលមានប្ដីជាវណ្ណៈសូទ្រៈ កូននោះត្រូវជាកំពុះជាចណ្ឌាល ទាបជាងបំផុតជាងសត្វតិរច្ឆានទៅទៀត ។ វណ្ណៈ ទាំង ៤ នេះ សុទ្ធតែមានគណៈបញ្ញត្តិ ជាអ្នកគ្រប់គ្រងក្រុមក្នុងវណ្ណៈរៀងៗខ្លួនជារ រហូតមកដល់សព្វថ្ងៃនេះ ។

តាមទស្សនៈថ្មីទៅ ការបែងចែកវណ្ណៈនេះ មិនមែនជាប្រពៃណីប្រសើរទេ ព្រោះមិនមែនជារចនាសង្គមប្រសើរ ជាហេតុនាំឲ្យបែកសាមគ្គីរវាងសង្គម មិនមែនជាហេតុនាំឲ្យកើតសាមគ្គីនិងសេចក្ដីសុខចំរើនទេ តែសព្វថ្ងៃនេះការប្រកាន់វណ្ណៈទន់ខ្សោយបន្តិចទៅខ្លះដែរ មិនមែននៅរឹងប៉ឹងដូចសម័យមនុដែលចងក្រងច្បាប់សម្រាប់ផងសម័យនោះទេ អាស្រ័យដោយ

ហេតុផ្សេង ៗ ដូចជាជនហិណ្ឌូទៅលាយឡំជាមួយនឹងជនជាតិដទៃឬលួចខ្ចិតដទៃ ៗ ដូចបុរស្ទិមជាដើម ឬដោយជនហិណ្ឌូជាន់ថ្មីដែលបានចូលយកវប្បធម៌ពីស្រុកក្រៅប្រទេស ក៏កើតមានគំនិតថ្មី ៗ ជាច្រើន ៗ គេឃើញថាវណ្ណៈទាំង ៤ ក្នុងកាលសព្វថ្ងៃនេះ ប្រៀបដូចជាការដ៏ជាក់ងឹងនោះ ដែលកំពុងលាយហរិជនបានចូលទៅក្នុងវិហារហិណ្ឌូ ហើយដើរមើលតាមចិត្តជនជនហិណ្ឌូខ្ពង់ខ្ពស់វណ្ណៈ ទៅតាមសណ្ឋាគារ មានការលាយឡំជាមួយជនជាតិផ្សេង ៗ កាន់សាសនាផ្សេង ៗ ដូចជាសាសនាគ្រិស្តជាដើម តែទៅតាមជនបទក្នុងប្រទេសឥណ្ឌាគេឃើញមានការប្រកាន់វណ្ណៈនៅឡើយច្រើនដែរ ព្រោះការសិក្សាសម័យថ្មី មិនទាន់ជ្រួតជ្រាបបរិបូណ៌ ៗ

X

X X

# អក្សរសាស្ត្រវេទ

| វេទ | | សាខា | សំហិតា | ព្រាហ្មណៈ | អារណ្យកៈ | ឧបនិសទ | កល្បសូត្រ |
|---|---|---|---|---|---|---|---|
| ឫគ្វេទ | | ឯតរេយិន | | ឯតរេយ | ឯតរេយ | ឯតរេយ | អាស្វលាយនៈ |
| | | កៅសីតកិន | ឫគ្សំហិតា | កៅសីតកី (សង្ខាយន) | កៅសីតកី | កៅសីតកី | សង្ខាយនៈ |
| យជុវេទ | ខ្មៅ | កាឋកៈ | កាឋកៈ | កាឋកៈ (មួយចំណែកនៅក្នុងតៃត្តិ.អារ.) | | តៃត្តិរីយ | បៅធាយនៈ |
| | | តៃត្តិរីយ | តៃត្តិរីយ | តៃត្តិរីយ | តៃត្តិរីយ | មហានារាយណៈ | Āpastamba- ហិរណ្យកេសិ |
| | | មៃត្រាយណីយ | មៃត្រាយណី | | | ស្វេតាស្វតរ | ភារទ្វាជ |
| | | កបិស្ថលកឋ | កបិស្ថល | | | | |
| | ស | មាធ្យន្ទិន | មាធ្យ.វាជសនេយី | ឝតបថ | មាធ្យ.វាជសនេយី | ព្រហទារណ្យក | កាត្យាយនៈ |
| | | កាណ្វៈ | កាណ្វីយ.វាជសនេយី | | កាណ្វីយ | ឦឝា | លាត្យាយនៈ |
| សាមវេទ | | កៅថុម | កៅថុមរាណាយនីយ | តណ្ឌ្យ បញ្ចវិំឝ | + | ឆាន្ទោគ្យ | គោភិល<br>ទ្រាហ្យ<br>សាមវិធានៈព្រាហ្មណ |
| | | តលវការ (ជៃមិនីយ) | ជៃមិនីយ | ជៃមិនីយ.តលវការ | + | កេន | ជៃមិនីយ |
| អថរ្វវេទ | | សៅនក | + | + | + | មុណ្ឌក<br>ប្រឝ្ន<br>មាណ្ឌូក្យ | កៅសិក<br>វៃតានសូត្រ |